មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

០៩-៦-២០១៣ -ព្រះរាជក្រម នស/រកម/០៦១៣/០១០ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើ :
១.កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការដឹកជញ្ជូនតាមផ្លូវសមុទ្រ
២. កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ
៣. ពិធីសារទី ៦ ស្តីពីស្ថានីយព្រំដែនផ្លូវដែក និងស្ថានីយប្តូរខ្សែរថភ្លើង ៥៤១៨

២. ព្រះរាជក្រឹត្យ

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៦៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ម្ចាស់ជំនួយ នៃអង្គការ JICA និងសប្បុរសជន ចំនួន ០៤ រូប ៥៤៩៣

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៦៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោក MYUNGIL KIM ប្រធានក្រុមហ៊ុន KTC Cable Co.,Ltd ៥៤៩៤

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៦៥ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែង ជូនមន្ត្រីរាជការស៊ីវិល ចំនួន ០២ រូប របស់ក្រសួងបរិស្ថាន ជាករណីពិសេស ៥៤៩៥

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៦៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ការពារជាតិ តាមលំដាប់ថ្នាក់ ចំពោះ នាយនគរបាលរង នាយនគរបាល និងនាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ២៧៨ រូប នៃក្រសួងមហាផ្ទៃ ៥៤៩៦

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៦៧ ស្តីពី ការផ្ទេរបញ្ចូលមន្ត្រីរាជការ ០១ រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៥៥០៥

៣០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៦៨ ស្តីពី ការតែងតាំងឯកឧត្តម **ឈិត បូរ៉ាឌុធ** ជាមេធាវីរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ៥៥០៦

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៨៤២,៧៤១១ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៤៨ គ្រួសារ បម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥៥០៧

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៧៦ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ១.០៦២,៨២៤៧ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៤៨១ គ្រួសារ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥៥១០

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៧៧ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៩៩,៧៣៣៥ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០៣ គ្រួសារ និងរក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥៥១៣

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៧៨ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ២.៧២៣,២២ ហិកតា នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីសម្បទានរបស់ក្រុមហ៊ុន ម៉ុង រិទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១.២៦៨ គ្រួសារ ៥៥១៦

២៩-៥-២០១៣ -អនុក្រឹត្យលេខ ២៧៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣.៩៨០,៤០ ហិកតា នៅស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៩៧ គ្រួសារ និងរក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥៥១៩

២. សារាចរណែនាំ

១១-៦-២០១៣ -សារាចរណែនាំលេខ ០៩ សរណន ស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ៥៥២២

ព្រះរាជក្រម

នស/រកម/០៦១៣/០១០

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាសឲ្យប្រើ

ច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើ ៖

- កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីការដឹកជញ្ជូនតាមផ្លូវសមុទ្រ
- កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្ដីពីការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ
- ពិធីសារទី៦ ស្ដីពីស្ថានីយព្រំដែនផ្លូវដែក និងស្ថានីយប្ដូរខ្សែរថភ្លើង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើ ៖

១. កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការដឹកជញ្ជូនតាមផ្លូវសមុទ្រ

២. កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ

៣. ពិធីសារទី៦ ស្តីពីស្ថានីយព្រំដែនផ្លូវដែកនិងស្ថានីយប្តូរខ្សែរថភ្លើង

មាត្រា ១.-

អនុម័តយល់ព្រមលើ ៖

១- កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការដឹកជញ្ជូនតាមផ្លូវសមុទ្រ ដែលបានធ្វើនៅប្រទេសសឹង្ហបុរី នាថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

២- កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ ដែលបានធ្វើនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩

៣- ពិធីសារទី៦ ស្តីពីស្ថានីយព្រំដែនផ្លូវដែកនិងស្ថានីយប្តូរខ្សែរថភ្លើង ដែលបានធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា ៣.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកម.០៦១៣.២០៨

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ហត្ថលេខា

ត្រាំ អ៊ីវតឹក

លេខៈ ៥៩៤ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

អគ្គលេខាធិការរងទទួលទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

កិច្ចព្រមព្រៀង
រវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ស្តីពី
ការដឹកជញ្ជូនតាមផ្លូវសមុទ្រ

....

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ សាធារណរដ្ឋសង្គមនិយមវៀតណាម ជាប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលតទៅមាននាមថា «ប្រទេសសមាជិកអាស៊ាន» ឬ «ភាគីកិច្ចសន្យា» ដែលជាភាគីម្ខាង និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលតទៅមាននាមថា «ចិន» ឬ «ភាគីកិច្ចសន្យា» ដែលជាភាគីម្ខាងទៀត ហើយដែលភាគីទាំងសងខាង តទៅមាននាមថា «ភាគីកិច្ចសន្យា»

យោងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូទៅ រវាងអាស៊ាន និងចិន ដែលបានចុះហត្ថលេខានាថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា

យោងអនុស្សរណៈនៃការយោគយល់ រវាងរដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីកិច្ចសហប្រតិបត្តិការដឹកជញ្ជូន ដែលបានចុះហត្ថលេខានាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

យោងផែនការសកម្មភាព ស្តីពីការអនុវត្តប្រកាសរួម ស្តីពីការពង្រឹងដៃគូភាពយុទ្ធសាស្ត្រអាស៊ាន-ចិន សំដៅសន្តិភាព សម្រាប់អរិយភាព ដែលបានចុះហត្ថលេខានាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

យោងសារៈសំខាន់នៃទំនាក់ទំនងនាវាចរណ៍សមុទ្រដែលកំពុងស្ថិតនៅជាធរមានរវាងប្រទេសសមាជិកអាស៊ាន និងចិន

ជឿជាក់ថាកិច្ចសហប្រតិបត្តិការលើវិស័យដឹកជញ្ជូនផ្លូវសមុទ្រជាលក្ខណៈអន្តរជាតិ រវាងភាគីកិច្ចសន្យា ផ្តល់ផលប្រយោជន៍ សម្រាប់អភិវឌ្ឍទំនាក់ទំនងពាណិជ្ជកម្ម និងសេដ្ឋកិច្ច រវាងប្រទេសសមាជិកអាស៊ាន-ចិន

ឆន្ទៈដើម្បីបន្តពង្រឹង និងរឹតចំណងទាក់ទង ដោយផ្អែកលើមូលដ្ឋានសមភាព និង ផលប្រយោជន៍ទៅវិញទៅមក នៅក្នុងវិស័យដឹកជញ្ជូនផ្លូវសមុទ្រជាលក្ខណៈអន្តរជាតិ

ទទួលស្គាល់អំពីសារៈសំខាន់នៃការដឹកជញ្ជូនផ្លូវសមុទ្រ ដើម្បីបង្កើនប្រសិទ្ធភាព ក្នុង

ចង្វាក់ដឹកជញ្ជូន

ឆន្ទៈដើម្បីបន្តសហការ និងទំនាក់ទំនងជាមួយគ្នា លុបបំបាត់របាំង ដែលរាំងស្ទះដល់ការដឹកជញ្ជូនផ្លូវសមុទ្រ និងបង្កើតប្រព័ន្ធក្របខ័ណ្ឌដឹកជញ្ជូនផ្លូវសមុទ្រតំបន់ ក្នុងគោលបំណងជំរុញការសម្របសម្រួលការដឹកជញ្ជូនផ្លូវសមុទ្រ

យោងកិច្ចព្រមព្រៀងនាវាចរណ៍ទ្វេភាគី ដែលកំពុងស្ថិតនៅជាធរមាន រវាងប្រទេសសមាជិកអាស៊ាន និងចិន

ភាគីទាំងសងខាង បានសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនេះ ដូចតទៅ៖

មាត្រា ១.~ គោលបំណង

កិច្ចព្រមព្រៀងនេះ មានគោលបំណងផ្តល់នូវការសម្របសម្រួល និងសហប្រតិបត្តិការក្នុងការកែលម្អលក្ខខណ្ឌទាំងឡាយ ដែលក្នុងនោះ ប្រតិបត្តិការដឹកជញ្ជូនទំនិញ និងប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរផ្លូវសមុទ្រ ប្រព្រឹត្តទៅបាន រវាងកំពង់ផែនៃភាគីកិច្ចសន្យា ក៏ដូចជារវាងកំពង់ផែនៃភាគីកិច្ចសន្យា និងកំពង់ផែនៃតតិយប្រទេស សម្រាប់ជាផលប្រយោជន៍នៃប្រតិបត្តិករសេដ្ឋកិច្ចរបស់ភាគីកិច្ចសន្យា។ ភាគីកិច្ចសន្យា ត្រូវទប់ស្កាត់រាល់សកម្មភាព ដែលអាចបំផ្លាញដល់ការចូលរួមដោយសេរីរបស់ក្រុមហ៊ុននាវានៃភាគីកិច្ចសន្យាលើការដឹកជញ្ជូនផ្លូវសមុទ្រ រវាងភាគីកិច្ចសន្យា ក៏ដូចជារវាងភាគីកិច្ចសន្យា និងតតិយប្រទេស។

មាត្រា ២.~ ដែនអនុវត្តន៍

១. កិច្ចព្រមព្រៀងនេះ អនុវត្តចំពោះការដឹកជញ្ជូនទំនិញ និងអ្នកដំណើរផ្លូវសមុទ្រជាលក្ខណៈអន្តរជាតិ រវាងកំពង់ផែនៃប្រទេសសមាជិកអាស៊ាន និងចិន។

២. កិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះការដឹកជញ្ជូនផ្លូវសមុទ្រជាលក្ខណៈក្នុងស្រុកសុទ្ធសាធ រវាងកំពង់ផែនានារបស់ចិន ឬ រវាងកំពង់ផែនានានៅក្នុងប្រទេសសមាជិកអាស៊ានណាមួយ។

៣. កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ដល់ការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ដែលបានធ្វើឡើងរវាងប្រទេសសមាជិកអាស៊ាននិងចិនសម្រាប់បញ្ហានានាដែលស្ថិតនៅក្រៅដែនអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ។

៤. កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ដល់សិទ្ធិរបស់នាវានៃតតិយភាគី ដើម្បីអនុវត្តការដឹកជញ្ជូនទំនិញនិងអ្នកដំណើរ រវាងកំពង់ផែនៃភាគីកិច្ចសន្យា ឬ រវាងកំពង់ផែនៃភាគីកិច្ចសន្យាណាមួយ និងតតិយភាគី។

មាត្រា ៣.~ និយមន័យ

ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

១. នាវា មានន័យថា នាវាជំនួញ ដែលបានចុះបញ្ជីស្របតាមច្បាប់នៃប្រទេសសមាជិកអាស៊ានណាមួយ ឬចិន នៅការិយាល័យចុះបញ្ជីនាវារបស់ភាគីកិច្ចសន្យាណាមួយ ក្រោមទង់ជាតិរបស់ភាគីកិច្ចសន្យានោះ និងបានប្រកបការដឹកជញ្ជូនផ្លូវសមុទ្រជាលក្ខណៈអន្តរជាតិ ដែលរួមទាំងនាវាពាក់ទង់ជាតិនៃតតិយប្រទេស ដែលកាន់កាប់ ឬ ប្រើប្រាស់ដោយក្រុមហ៊ុន

នាវារបស់ប្រទេសសមាជិកអាស៊ាននណាមួយ ឬចិន។ ប៉ុន្តែ ពាក្យនេះ មិនរាប់បញ្ចូលនាវាចម្បាំង និងនាវាមិនបម្រើពាណិជ្ជកម្មឡើយ។

២. សមាជិកនាវិក មានន័យថា មេបញ្ជាការនាវា ឬ បុគ្គលណាមួយ ដែលបម្រើការងារនៅលើនាវា មានឈ្មោះនៅក្នុងបញ្ជីនាវិក និងកាន់ឯកសារសម្គាល់ខ្លួនដែលមានសុពលភាពចេញដោយ ឬទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់មេបញ្ជាការនាវា ឬបុគ្គលនោះ។

៣. កំពង់ផែ មានន័យថា កំពង់ផែសមុទ្រ រួមមានទាំងទីចំណត នៅក្នុងដែនដីនៃប្រទេសសមាជិកអាស៊ាននណាមួយ ឬចិន ដែលបានអនុម័តយល់ព្រម និងបើកឲ្យប្រើប្រាស់សម្រាប់នាវាចរណ៍ជាលក្ខណៈអន្តរជាតិ។

៤. ក្រុមហ៊ុននាវា ជាសហគ្រាស ដែលបំពេញនូវលក្ខខណ្ឌទាំងឡាយ ដូចខាងក្រោម៖

ក. បង្កើតឡើងស្របតាមច្បាប់នៃប្រទេសសមាជិកអាស៊ាននណាមួយ ឬចិន

ខ. មានការិយាល័យចុះបញ្ជី ឬការិយាល័យមេ នៅក្នុងប្រទេសសមាជិកអាស៊ាននណាមួយ ឬចិន

គ. ប្រកបសេវានាវាចរណ៍ជាលក្ខណៈអន្តរជាតិ ដោយមាននាវារបស់ខ្លួនផ្ទាល់ប្រើប្រាស់ ឬ ធ្វើប្រតិបត្តិការនាវា

ឃ. ជានីតិបុគ្គលឯករាជ្យ ស្របតាមច្បាប់របស់ប្រទេសសមាជិកអាស៊ាននណាមួយ ឬចិន។

មាត្រា ៤.- ប្រព្រឹត្តកម្មនៅកំពង់ផែ

ភាគីកិច្ចសន្យានីមួយៗ ត្រូវផ្តល់ឲ្យនាវា សមាជិកនាវិក អ្នកដំណើរ និងទំនិញនៅលើនាវារបស់ភាគីកិច្ចសន្យាម្ខាងទៀត នូវប្រព្រឹត្តកម្ម មិនតិចជាងប្រព្រឹត្តកម្ម ដែលបានផ្តល់ឲ្យនាវារបស់តតិយប្រទេសឡើយ ពាក់ព័ន្ធនឹង៖

ក. ការចូលទៅកាន់កំពង់ផែដែលបានបើកឲ្យប្រើប្រាស់សម្រាប់នាវាចរណ៍ជាលក្ខណៈអន្តរជាតិ

ខ. ការស្នាក់អាស្រ័យនៅកំពង់ផែ និងការចាកចេញពីកំពង់ផែ

គ. ការប្រើប្រាស់បរិក្ខារបនីយភណ្ឌផែ និងបរិក្ខារបនីយភណ្ឌផ្សេងទៀតនៅកំពង់ផែ សម្រាប់ការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ក៏ដូចជាការទទួលសេវានានា

ឃ. ការប្រមូលថ្លៃឈ្នួល និងកម្រៃផែ។

មាត្រា ៥.- ការសម្របសម្រួលដឹកជញ្ជូន

ក្នុងដែនអនុវត្តន៍នៃច្បាប់ វិធាន និងបទបញ្ញារបស់ខ្លួន ភាគីកិច្ចសន្យា ត្រូវចាត់វិធានការសមស្របទាំងឡាយ ដើម្បីចៀសវាងការពន្យារពេលដែលមិនចាំបាច់ ក៏ដូចជាដើម្បីធ្វើឲ្យឆាប់ និងងាយស្រួល នូវបែបបទរដ្ឋបាល គយ អនាម័យ និងបែបបទផ្សេងៗទៀត ដែលកំពុងធរមាននៅកំពង់ផែរបស់ខ្លួន។

មាត្រា ៦.- ឯកសាររបស់នាវា

១. ភាគីកិច្ចសន្យានីមួយៗ ត្រូវទទួលស្គាល់វិញ្ញាបនបត្រចុះបញ្ជី/វិញ្ញាបនបត្រសញ្ជាតិ និងឯកសារផ្សេងៗទៀតរបស់នាវា ដែលកាន់កាប់ដោយនាវារបស់ភាគីកិច្ចសន្យាម្ខាងទៀត និងចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់សញ្ជាតិ។

២. នាវារបស់ភាគីកិច្ចសន្យាមួយ ដែលកាន់កាប់វិញ្ញាបនបត្រទម្ងន់ផ្ទុក ដែលមានសុពលភាព ចេញឲ្យស្របតាមអនុសញ្ញាអន្តរជាតិ ស្តីពីរង្វាស់ទម្ងន់ផ្ទុកនាវាឆ្នាំ១៩៦៩ និងវិសោធនកម្មនៃអនុសញ្ញានេះ និងទទួលស្គាល់ដោយភាគីកិច្ចសន្យាម្ខាងទៀតនោះ មិនត្រូវវាស់ឡើងវិញនៅតាមកំពង់ផែនៃភាគីកិច្ចសន្យានោះឡើយ។ អាករ និងកម្រៃផ្សេងៗ ដែលផ្អែកលើទម្ងន់ផ្ទុករបស់នាវា ត្រូវគិត និងប្រមូលយក ស្របតាមវិញ្ញាបនប័ត្រ ដូចមានចែងខាងលើ។

មាត្រា ៧.- ការឡើងគោក ការចូល ការចាកចេញ និងការឆ្លងកាត់របស់សមាជិកនាវិក

១. ស្របតាមច្បាប់ វិធាន និងបទបញ្ជាជាធរមានរបស់ខ្លួន ភាគីកិច្ចសន្យាណាមួយ ត្រូវទទួលស្គាល់ឯកសារសម្គាល់ខ្លួនរបស់សមាជិកនាវិក ដែលចេញឲ្យ ឬ ទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីកិច្ចសន្យាម្ខាងទៀត។

២. ស្របតាមច្បាប់ វិធាន និងបទបញ្ជាជាធរមានរបស់ខ្លួន ភាគីកិច្ចសន្យាណាមួយ ត្រូវអនុញ្ញាតឲ្យសមាជិកនាវិករបស់នាវានៃភាគីកិច្ចសន្យាម្ខាងទៀត ដែលកាន់ឯកសារសម្គាល់ខ្លួនដែលមានសុពលភាព ដូចមានចែងនៅក្នុងមាត្រា៣ ដើម្បីឡើងគោក និងស្នាក់អាស្រ័យនៅតំបន់ក្រុងកំពង់ផែ ក្នុងអំឡុងពេលស្នាក់អាស្រ័យនៅរបស់នាវា នៅកំពង់ផែណាមួយនៃភាគីកិច្ចសន្យានោះ។

៣. ស្របតាមច្បាប់ វិធាន និងបទបញ្ជាជាធរមានរបស់ខ្លួន ភាគីកិច្ចសន្យាណាមួយ ត្រូវអនុញ្ញាតឲ្យសមាជិកនាវិករបស់ភាគីកិច្ចសន្យាម្ខាងទៀត ដែលកាន់ឯកសារសម្គាល់ខ្លួនដែលមានសុពលភាព ដើម្បីចូល ចេញ ឬឆ្លងកាត់ដែនដី តាមមធ្យោបាយចរាចរណ៍ណាមួយ ក្នុងដំណើរមាតុភូមិនិវត្តន៍ ឬ បម្រើការនៅលើនាវា ឬ ហេតុផលផ្សេងទៀត ដែលអាជ្ញាធរមានសមត្ថកិច្ចនៃភាគីកិច្ចសន្យានោះ អាចទទួលយកបាន។

៤. ស្របតាមច្បាប់ វិធាន និងបទបញ្ជាជាធរមានរបស់ខ្លួន ភាគីកិច្ចសន្យាណាមួយ ត្រូវរក្សាសិទ្ធិបដិសេធរាល់ការចូល និងស្នាក់អាស្រ័យនៅនៅក្នុងដែនដីរបស់ខ្លួន ចំពោះសមាជិកនាវិកណាមួយបាន បើសិនជាភាគីកិច្ចសន្យានោះ អាចចាត់ទុកថាមិនសមស្រប។

មាត្រា ៨.- យុត្តាធិការនៅលើនាវា

១. ភាគីកិច្ចសន្យាណាមួយ មិនត្រូវអនុវត្តយុត្តាធិការព្រហ្មទណ្ឌនៅលើនាវានៃភាគីកិច្ចសន្យាម្ខាងទៀត ដែលកំពុងឆ្លងកាត់សមុទ្រដែនដីរបស់ខ្លួន ដើម្បីចាប់ជនណាមួយ ឬ ដើម្បីធ្វើការស៊ើបអង្កេតណាមួយពីបទព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តនៅលើនាវានោះ ក្នុងអំឡុងពេលនៃការធ្វើដំណើរឆ្លងកាត់បានឡើយ វៀរលែងតែក្នុងករណីដូចខាងក្រោម៖

ក. ប្រសិនបើផលវិបាកនៃបទព្រហ្មទណ្ឌនោះ រាលដាលដល់ភាគីកិច្ចសន្យានោះ

ខ. ប្រសិនបើបទព្រហ្មទណ្ឌនោះ ជាប្រភេទបទល្មើស បង្កឲ្យបាត់បង់សន្តិភាពរបស់ភាគីកិច្ចសន្យានោះ ឬ ធ្វើឲ្យខូចរបៀបរៀបរយល្អនៃសមុទ្រដែនដីរបស់ភាគីកិច្ចសន្យានោះ

គ. ប្រសិនបើមានការស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋាន ដែលធ្វើឡើងដោយមេបញ្ជាការនាវា ឬ ដោយភ្នាក់ងារការទូត ឬ ដោយមន្ត្រីកុងស៊ុលនៃភាគីកិច្ចសន្យា

ឃ. ប្រសិនបើវិធានការទាំងឡាយ ដែលចាំបាច់សម្រាប់បង្ក្រាបចរាចរណ៍ថ្នាំញៀន ឬ សារធាតុពង្វក់ស្មារតី។

២. បទប្បញ្ញត្តិខាងលើនេះ មិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីកិច្ចសន្យា ដើម្បីចាត់វិធានការ ដែលច្បាប់ វិធាន និងបទបញ្ជារបស់ភាគីនោះ បានអនុញ្ញាត ក្នុងគោលបំណងចាប់ ឬ ស៊ើបអង្កេតនៅលើនាវារបស់ភាគីកិច្ចសន្យាម្ខាងទៀត ដែលកំពុងធ្វើដំណើរឆ្លងកាត់សមុទ្រដែនដី ក្រោយពេលដែលនាវានោះ ចាកចេញពីដែនទឹកផ្ទៃក្នុង។

៣. នៅក្នុងករណី ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ និងទី២ ហើយបើសិនជាមេបញ្ជាការនាវាបានស្នើសុំ ភាគីកិច្ចសន្យាត្រូវជូនដំណឹងទៅភ្នាក់ងារទូត ឬ មន្ត្រីកុងស៊ុលរបស់ភាគីកិច្ចសន្យាម្ខាងទៀត មុនពេលចាត់វិធានការនោះ និងត្រូវសម្របសម្រួលទំនាក់ទំនងរវាងភ្នាក់ងារ ឬ មន្ត្រីនោះ និងនាវិកនៃនាវា។ ក្នុងករណីបន្ទាន់ ការជូនដំណឹងនេះ អាចធ្វើឡើងក្នុងពេលដែលកំពុងចាត់វិធានការ។

៤. ក្នុងការពិចារណាតាមទម្រង់ណាមួយ ដែលអាចធ្វើការចាប់នោះ អាជ្ញាធរមូលដ្ឋានត្រូវយកចិត្តទុកដាក់អំពីផលប្រយោជន៍នៃនាវាចរណ៍។

៥. លើកលែងតែមានចែងនៅក្នុងវិធានការ និងគោលការណ៍អន្តរជាតិជាធរមាន ដែលគ្រប់គ្រង ការពារ និងអភិរក្សបរិស្ថានសមុទ្រ ឬ ដែលពាក់ព័ន្ធនឹងបទល្មើសច្បាប់ វិធាន និងបទបញ្ជានានាដែលបានអនុម័តស្របតាមបទប្បញ្ញត្តិដោយឡែក និងសិទ្ធិយុត្តាធិការ និងកាតព្វកិច្ចរបស់រដ្ឋតំបន់ឆ្នេរ និងរដ្ឋផ្សេងៗទៀត នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ទើបភាគីកិច្ចសន្យា អាចមិនចាត់វិធានការណាមួយនៅលើនាវារបស់ភាគីកិច្ចសន្យាម្ខាងទៀត ដែលកំពុងធ្វើដំណើរឆ្លងកាត់សមុទ្រដែនដី ដើម្បីចាប់ជនណាមួយ ឬ ដើម្បីធ្វើការស៊ើបអង្កេតពីបទព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តនៅលើនាវា មុនពេលដែលនាវាចូលក្នុងសមុទ្រដែនដីបាន ប្រសិនបើនាវាដែលធ្វើដំណើរចេញពីកំពង់ផែបរទេសនោះ គ្រាន់តែធ្វើដំណើរឆ្លងកាត់សមុទ្រដែនដីដោយមិនចូលក្នុងដែនទឹកផ្ទៃក្នុង។

មាត្រា ៩.~ ការចំណាយ និងការផ្ទេរប្រាក់

១. ប្រាក់ចំណូលរបស់ក្រុមហ៊ុននាវានៃភាគីកិច្ចសន្យាណាមួយ ដែលកើតចេញពីការដឹកជញ្ជូនផ្លូវសមុទ្រជាលក្ខណៈអន្តរជាតិ នៅក្នុងភាគីកិច្ចសន្យាម្ខាងទៀត អាចធ្វើឡើងតាមរូបិយបណ្ណបង្វែរសេរី ឬ រូបិយបណ្ណប្រើប្រាស់សេរី ស្របតាមបទប្បញ្ញត្តិប្តូរប្រាក់ ដែលកំពុងធរមាននៅក្នុងភាគីកិច្ចសន្យានោះ។

២. ក្រុមហ៊ុននាវានៃភាគីកិច្ចសន្យាមួយ មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញពីសេវាកម្ម

នាវាចរណ៍ ដែលកើតឡើងនៅក្នុងដែនដីនៃភាគីកិច្ចសន្យាម្ខាងទៀត សម្រាប់ការចំណាយពាក់ព័ន្ធនឹងនាវាចរណ៍នោះ ស្របតាមច្បាប់ វិធាន និងបទបញ្ញាជាធរមានរបស់ភាគីកិច្ចសន្យានោះ។ ប្រាក់ចំណូល អាចត្រូវបានផ្ទេរទៅក្រៅ តាមរូបិយបណ្ណបង្វែរសេរី ឬ រូបិយបណ្ណប្រើប្រាស់សេរី ស្របតាមបទប្បញ្ញត្តិប្ដូរប្រាក់ ដែលកំពុងធរមាននៅក្នុងភាគីកិច្ចសន្យានោះ។

មាត្រា ១០.- កិច្ចសហប្រតិបត្តិការនាវាចរណ៍សមុទ្រ

ក្នុងគោលបំណងជំរុញការអភិវឌ្ឍឧស្សាហកម្មនាវាចរណ៍សមុទ្រ ឲ្យស្របតាមច្បាប់ វិធាន និងបទបញ្ញានានារបស់ខ្លួន ភាគីកិច្ចសន្យា ត្រូវជំរុញអាជ្ញាធរមានសមត្ថកិច្ច ក្រុមហ៊ុននាវា កំពង់ផែ ស្ថាប័នស្រាវជ្រាវពាក់ព័ន្ធ មហាវិទ្យាល័យ សកលវិទ្យាល័យ និងស្ថាប័នបណ្ដុះបណ្ដាល និងអប់រំនាវាចរណ៍របស់ខ្លួន ឲ្យចូលរួមសហការលើផ្នែកនានា ដែលមានជាអាទិ៍៖

ក. ផ្លាស់ប្ដូរទស្សនៈអំពីបញ្ហាដែលពាក់ព័ន្ធនឹងសកម្មភាពដឹកជញ្ជូនផ្លូវសមុទ្រ

ខ. ផ្លាស់ប្ដូរពត៌មានអំពីច្បាប់ និងបទបញ្ញានានា ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនផ្លូវសមុទ្រ

គ. ជំរុញឲ្យមានប្រសិទ្ធភាពលើសេវាកម្មដឹកជញ្ជូន សម្រាប់ពាណិជ្ជកម្មនាវាចរណ៍សមុទ្រជាលក្ខណៈអន្តរជាតិ តាមរយៈអភិបាលកិច្ចកំពង់ផែ និងនាវានៃភាគីកិច្ចសន្យា ប្រកបដោយប្រសិទ្ធភាព

ឃ. លើកកម្ពស់សុវត្ថិភាពនាវាចរណ៍សមុទ្រ និងកិច្ចការពារបរិស្ថានសមុទ្រ ទល់នឹងការបំពុល

ង. ជំរុញការអប់រំនិងបណ្ដុះបណ្ដាលនាវាចរណ៍ជាពិសេសការបណ្ដុះបណ្ដាលនាវិក និងគ្រូបង្ហាត់នាវិក

ច. ផ្លាស់ប្ដូរមន្ត្រីជំនាញ និងបច្ចេកវិទ្យានាវាចរណ៍សមុទ្រ

ឆ. លើកកម្ពស់កិច្ចសហប្រតិបត្តិការ ដើម្បីកែលម្អសន្តិសុខនាវាចរណ៍សមុទ្រ រួមទាំងការអនុវត្តបទប្បញ្ញត្តិនៃក្រមអន្តរជាតិស្ដីពីសន្តិសុខនាវា និងបរិយាកាសកំពង់ផែ។

មាត្រា ១១.- ការពិគ្រោះយោបល់រវាងគ្នា

១. ក្នុងគោលបំណងសហប្រតិបត្តិការជិតស្និត ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះឲ្យមានប្រសិទ្ធភាព និងផ្អែកតាមការស្នើសុំរបស់ប្រទេសសមាជិកអាស៊ានណាមួយ ឬ ចិន តំណាងនានាមកពីភាគីកិច្ចសន្យា អាចជួបប្រជុំគ្នា ដើម្បីពិភាក្សាលើសំណើ ដែលផ្ញើជូនដោយភាគីកិច្ចសន្យាណាមួយ តាមកាលបរិច្ឆេទ និងទីកន្លែង ដែលបានយល់ព្រមរវាងគ្នា។ កិច្ចប្រជុំពិគ្រោះយោបល់នេះ ត្រូវធ្វើឡើងមិនលើសពី៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើ។

២. លេខាធិការដ្ឋានអាស៊ាន និងក្រសួងគមនាគមន៍ចិន ត្រូវជួយក្នុងការរៀបចំបើកកិច្ចប្រជុំពិគ្រោះយោបល់ដែលបានស្នើឡើងនោះ។

មាត្រា ១២.- ដំណោះស្រាយជម្លោះ

វិវាទ ឬ ភាពខ្វែងគ្នា ដែលកើតឡើងពីការបកស្រាយ ឬ ការអនុវត្ត ឬ ការប្រតិបត្តិការតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយដោយសន្តិភាពតាមរយៈការពិគ្រោះយោបល់ ឬ ការចរចារវាងភាគីកិច្ចសន្យា។

មាត្រា ១៣.- ការសម្ងាត់

ពត៌មានសម្ងាត់ណាមួយ ឯកសារសម្ងាត់ណាមួយ ឬ ទិន្នន័យសម្ងាត់ណាមួយ ដែលបានទទួល ស្របតាមកិច្ចព្រមព្រៀងនេះ មិនត្រូវផ្សព្វផ្សាយ ឬ ចែកចាយឲ្យទៅតតិយភាគីបានឡើយ លើកលែងតែមានការអនុញ្ញាត តាមទម្រង់ជាលាយលក្ខអក្សរ ដើម្បីធ្វើដូចនោះដោយភាគីកិច្ចសន្យា ដែលផ្ដល់ពត៌មាន ឯកសារ ឬ ទិន្នន័យសម្ងាត់នោះ។

មាត្រា ១៤.- ការចូលជាធរមាន រយៈពេល និងវិសោធនកម្ម

១. ក្រោយការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះមក ប្រទេសសមាជិកអាស៊ាននីមួយៗ ត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅអគ្គលេខាធិការអាស៊ាន ដែលជាអ្នកជូនពត៌មាននេះជាបន្ទាន់ទៅចិន នៅពេលដែលប្រទេសសមាជិកអាស៊ានទាំងអស់ បានបញ្ចប់នីតិវិធីផ្ទៃក្នុងនោះ រួចរាល់ហើយ។

២. ក្រោយការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួន សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ចិនត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅអគ្គលេខាធិការអាស៊ាន។

៣. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន នៅពេលដែលបានទទួលការជូនដំណឹងជាលាយលក្ខអក្សរចុងក្រោយ។ អគ្គលេខាធិការអាស៊ាន ត្រូវជូនដំណឹងទៅប្រទេសសមាជិកអាស៊ានទាំងអស់ អំពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

៤. កិច្ចព្រមព្រៀងនេះ ត្រូវបានសម្រេចព្រមព្រៀងគ្នាសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ។ កិច្ចព្រមព្រៀងនេះ មានសុពលភាពឡើងវិញដោយស្វ័យប្រវត្តិ សម្រាប់រយៈពេល១(មួយ)ឆ្នាំម្ដង វៀរលែងតែភាគីកិច្ចសន្យាមួយ ក្នុងចំណោមភាគីកិច្ចសន្យាទាំងអស់ បដិសេធជាលាយលក្ខអក្សរក្នុងរយៈពេល៦(ប្រាំមួយ)ខែ មុនកាលបរិច្ឆេទផុតកំណត់។

៥. ភាគីកិច្ចសន្យានីមួយៗ អាចស្នើសុំជាលាយលក្ខអក្សរ ដើម្បីធ្វើវិសោធនកម្មលើបទប្បញ្ញត្តិទាំងមូល ឬបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ។ ការធ្វើវិសោធនកម្មនោះត្រូវមានការយល់ព្រមរវាងគ្នាជាលាយលក្ខអក្សរដោយភាគីកិច្ចសន្យា និងត្រូវបង្កើតឡើងជាផ្នែកសមាហរណ៍នៃកិច្ចព្រមព្រៀងនេះ។ ការធ្វើវិសោធនកម្មនេះ ត្រូវចូលជាធរមានភ្លាម តាមកាលបរិច្ឆេទ ដែលយល់ព្រមជាលាយលក្ខអក្សរដោយភាគីកិច្ចសន្យាទាំងអស់។

មាត្រា ១៥.- ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវសមុទ្រទ្វេភាគីដែលកំពុងធរមាន

ប្រសិនបើបទប្បញ្ញត្តិណាមួយ នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីដែលកំពុងធរមាន រវាងចិន និងប្រទេសសមាជិកអាស៊ានណាមួយ តម្រូវឲ្យភាគីទាំងនោះ ផ្ដល់បន្ថែមនូវប្រព្រឹត្តកម្ម

ច្រើនជាងប្រព្រឹត្តកម្ម ដែលតម្រូវឲ្យមានតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ បទប្បញ្ញត្តិនោះត្រូវមានអំណាចគតិយុត្តលើកិច្ចព្រមព្រៀងនេះ តែចំពោះចិន និងប្រទេសសមាជិកអាស៊ាននោះតែប៉ុណ្ណោះ។ បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវជំនួសរាល់កិច្ចព្រមព្រៀងទ្វេភាគីមុនទាំងឡាយណា ដែលធ្វើឡើងរវាងប្រទេសអាស៊ាន និងចិន ប្រសិនបើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងទ្វេភាគីនោះ មិនស្របនឹងកិច្ចព្រមព្រៀងនេះ វៀរលែងតែស្ថានភាព ដូចមានចែងនៅក្នុងកថាខ័ណ្ឌខាងលើ ឬស្ថានភាពស្រដៀងគ្នានឹងកថាខ័ណ្ឌខាងលើនោះ។

មាត្រា ១៦.~ កិច្ចការពារសន្តិសុខជាតិនិងសុខភាពសាធារណៈ

បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ មិនកម្រិតសិទ្ធិរបស់ចិននិងប្រទេសសមាជិកអាស៊ានណាមួយ ដើម្បីចាត់វិធានការនានា សម្រាប់កិច្ចការពារសន្តិសុខ និងសុខភាពសាធារណៈរបស់ខ្លួន ឬ ការបង្ការជំងឺឆ្លង និងមេរោគនៅក្នុងសត្វ និងរុក្ខជាតិឡើយ។

ដើម្បីជាសក្ខីភាព ភាគីហត្ថលេខីខាងក្រោម ដែលបានទទួលការអនុញ្ញាតស្របច្បាប់ពីរដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើនៅសឹង្ហបុរី ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០៧ ជាពីរច្បាប់ដើម ជាភាសាអង់គ្លេស។

ចំពោះប្រទេសសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះ ត្រូវតំកល់ទុកនៅលេខាធិការដ្ឋានអាស៊ានដែលជាអ្នកបញ្ជូនជាបន្ទាន់នូវសេចក្តីថតចម្លងត្រឹមត្រូវទៅប្រទេសសមាជិកអាស៊ានទាំងអស់។

ក្នុងនាមរដ្ឋាភិបាលប្រទេសប្រ៊ុយណេ
....
ឯកឧត្តម ប៉េហ៊ីន ដាតូអាប៊ូបាការអាពុង
រដ្ឋមន្ត្រីក្រសួងគមនាគមន៍

ក្នុងនាមរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
....
ឯកឧត្តម លី សេងលីន
រដ្ឋមន្ត្រីក្រសួងគមនាគមន៍

ក្នុងនាមព្រះរាជាណាចក្រកម្ពុជា
....
ឯកឧត្តម ស៊ុន ចាន់ថុល
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ក្នុងនាមរដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូនេស៊ី
....
ឯកឧត្តម យ៉ាសម៉ាន ស៊ីយ៉ាហ្វី ឌយ៉ាម៉ាល
រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន

ក្នុងនាមរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

....

ឯកឧត្តម សុំម៉ាត ប៉ុលស៊ីណា
រដ្ឋមន្ត្រីក្រសួងគមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ៍និងសំណង់

ក្នុងនាមរដ្ឋាភិបាលម៉ាឡេស៊ី

....

ឯកឧត្តម ដាតូ ស្រីចាន់កុងចយ
រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន

ក្នុងនាមរដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

....

ឯកឧត្តមឧត្តមសេនីយ៍ឯក គេអ៊ីន ស្វី
រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន

ក្នុងនាមរដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

....

ឯកឧត្តមឧត្តមសេនីយ៍ លីនត្រូ អា មែនដូសា
រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន និងគមនាគមន៍

ក្នុងនាមរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

....

ឯកឧត្តម ល៉េម៉ុន លឹម
រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន

ក្នុងនាមរាជរដ្ឋាភិបាលថៃឡង់ដ៍

....

ឯកឧត្តមឧត្តមនាវឯក ធីរ៉ា ហាវចារឿន
រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន

ក្នុងនាមរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

....

ឯកឧត្តម ត្រាន់ ដូនតុ
អនុរដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន

asean

AGREEMENT ON MARITIME TRANSPORT BETWEEN THE GOVERNMENTS OF THE MEMBER COUNTRIES OF THE ASSOCIATION OF SOUTHEAST ASIAN NATIONS AND THE GOVERNMENT OF THE PEOPLE'S REPUBLIC OF CHINA

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic ("Lao PDR"), Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, the Socialist Republic of Viet Nam as Member Countries of the Association of Southeast Asian Nations (hereinafter referred to as "Member Countries of ASEAN" or collectively "a Contracting Party") on the one side, and the Government of the People's Republic of China (hereinafter referred to as "China" or "a Contracting Party") on the other; and both sides hereinafter referred to collectively as "Contracting Parties";

TAKING INTO ACCOUNT the Framework Agreement on the Comprehensive Economic Cooperation between ASEAN and China, signed on 4th November 2002 in Phnom Penh, Cambodia;

TAKING INTO ACCOUNT the Memorandum of Understanding between the Governments of the Member Countries of ASEAN and the Government of the People's Republic of China on Transport Cooperation signed on 27th November 2004 in Vientiane, Lao PDR;

TAKING INTO ACCOUNT the Plan of Action on Implementing the Joint Declaration on Strengthening ASEAN-China Strategic Partnership towards Peace for Prosperity signed on 29th November 2004 in Vientiane, Lao PDR;

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

TAKING INTO ACCOUNT the importance of the maritime relations existing between the Member Countries of ASEAN and China;

BELIEVING that cooperation in the international maritime transport field between the Contracting Parties will be beneficial for the development of the trade and economic relations between the Member Countries of ASEAN and China;

WILLING to further strengthen and consolidate the relations, on the basis of equality and mutual benefits in the field of international maritime transport;

RECOGNISING the importance of maritime transport in order to increase efficiencies in the transport chain;

WILLING to further cooperate and communicate with each other, eliminate barriers hindering maritime transport, and establish regional maritime transport framework system with the aim to promote maritime transport facilitation;

TAKING INTO ACCOUNT the existing bilateral maritime agreements between the Member Countries of ASEAN and China;

HAVE AGREED as follows:

ARTICLE 1
AIM

This Agreement is aimed at providing facilitation and cooperation in improving the conditions under which maritime cargo and passenger transport operations are carried out between the ports of the Contracting Parties, as well as between the ports of the Contracting Parties and the ports of third countries, for the benefit of economic operators of the Contracting Parties. The Contracting Parties shall refrain from any action that might be detrimental to the

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

unrestricted participation of shipping companies of the Contracting Parties in maritime transport between the Contracting Parties as well as between the Contracting Parties and third countries.

ARTICLE 2
SCOPE

1. This Agreement applies to the international maritime cargo and passenger transport between the ports of the Member Countries of ASEAN and China.

2. This Agreement shall not apply to domestic maritime transport purely between the ports within any Member Country of ASEAN or between the ports of China.

3. This Agreement shall not affect the application of the bilateral agreements concluded between the Member Countries of ASEAN and China for issues falling outside the scope of this Agreement.

4. This Agreement shall not affect the right of vessels of third parties to engage in cargo and passenger transport between the ports of the Contracting Parties or between the ports of either Contracting Party and a third party.

ARTICLE 3
DEFINITION

For the purpose of this Agreement:

1. "vessel" means any merchant ship registered in accordance with the laws of a Member Country of ASEAN or China in the vessel registration office of either Contracting Party under the national flag of that Contracting Party and engaged in international maritime transport, including vessels flying the flag of a third country but owned or operated by a shipping company of a Member Country of ASEAN or China. However, this term shall not include warships and any other non-commercial ships.

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

2. "crew member" means the master or any person employed on board a vessel, in duties and services connected with the running of the vessel and whose name is included in the crew list and holds a valid identity document issued or recognised by the competent authorities of his/her country.

3. "ports" means seaports including roadsteads, in the territory of a Member Country of ASEAN or China which are approved and open to international shipping.

4. "shipping company" is an enterprise which meets all of the following conditions:

a) being established in accordance with the laws, rules and regulations of a Member Country of ASEAN or China;
b) having its registered office or head office in a Member Country of ASEAN or China;
c) engaging in international shipping services with its own or operated vessels; and
d) being an independent legal entity in accordance with the laws, rules and regulations of a Member Country of ASEAN or China.

ARTICLE 4
TREATMENT IN PORTS

Each Contracting Party shall grant the vessels of the other Contracting Party, their crew members, passengers and cargoes on board the treatment no less favorable than granted to vessels of a third country in regard to:

a) the access to ports open to international maritime traffic;
b) the stay in ports and departure therefrom;
c) the use of port facilities for cargoes and passengers transport as well as regarding the access to any services and other facilities available in ports;
d) the collection of fees and port charges.

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

ARTICLE 5
FACILITATION OF TRANSPORT

The Contracting Parties shall, within the limits of their respective laws, rules and regulations, take all appropriate measures to avoid any unnecessary delay as well as to expedite and simplify the administrative, customs, sanitary and other formalities in force in their ports.

ARTICLE 6
SHIP'S DOCUMENTS

1. Each Contracting Party shall recognise the certificates of registry/nationality and other ship's documents held by vessels of the other Contracting Party and issued by the competent authorities of the flag state.

2. Vessels of one Contracting Party holding valid tonnage certificates issued in compliance with the International Convention on Tonnage Measurement of Ships, 1969, as amended, and accepted by the other Contracting Party shall not be re-measured in the ports of the other Contracting Party. All the dues and charges based on the tonnage of vessels shall be calculated and collected in accordance with the above-mentioned certificates.

ARTICLE 7
ASHORE, ENTRY, DEPARTURE AND TRANSIT BY CREW MEMBERS

1. Either Contracting Party shall, in accordance with its laws, rules and regulations in force, recognise the identity documents of the crew members, issued or recognised by the competent authorities of the other Contracting Party.

2. Either Contracting Party shall allow, in accordance with its laws, rules and regulations in force, crew members of a vessel of the other Contracting Party, who hold the valid identity documents, as referred to in Article 3, to go ashore

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

and to stay in the port town area during the stay of their vessel in any of its ports.

3. Either Contracting Party shall allow, in accordance with its laws, rules and regulations in force, crew members of the other Contracting Party, who hold a valid identity document, to enter, leave, or pass through its territory, by means of any traffic, on account of repatriation, joining a vessel or other reasons acceptable to its competent authorities.

4. Either Contracting Party, in accordance with its laws, rules and regulations in force, reserves the right to deny the entry into and stay within its territory of any crew members it may regard as undesirable.

ARTICLE 8
JURISDICTION ON BOARD VESSELS

1. Either Contracting Party shall not exercise criminal jurisdiction on board vessels of another Contracting Party passing through their territorial sea to arrest any person or to conduct any investigation in connection with any crime committed on board the vessels during their passage, save only in the following cases:

a) if the consequences of the crime extend to the Contracting Party;
b) if the crime is of a kind to disturb the peace of the Contracting Party or the good order of its territorial sea;
c) if the assistance of the local authorities has been requested by the master of the vessel or by a diplomatic agent or consular officer of the Contracting Party; or
d) if such measures are necessary for the suppression of illicit traffic in narcotic drugs or psychotropic substances.

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

2. The above provisions do not affect the right of the Contracting Party to take any steps authorised by its laws, rules and regulations for the purpose of an arrest or investigation on board vessels of another Contracting Party passing through the territorial sea after leaving internal waters.

3. In the cases provided for in paragraphs 1 and 2, the Contracting Party shall, if the master so requests, notify a diplomatic agent or consular officer of the other Contracting Party before taking any steps, and shall facilitate contact between such agent or officer and the vessel's crew. In cases of emergency, this notification may be communicated while the measures are being taken.

4. In considering whether or in what manner an arrest should be made, the local authorities shall have due regard to the interests of navigation.

5. Except as provided for in internationally adopted rules and principles: (a) governing the protection and preservation of the marine environment; or (b) with respect to violations of laws, rules and regulations adopted in relation to the specific legal regime, and the rights, jurisdiction and duties of the coastal and other states in the exclusive economic zones; the Contracting Party may not take any steps on board vessels of another Contracting Party passing through the territorial sea to arrest any person or to conduct any investigation in connection with any crime committed before the vessel entered the territorial sea, if the vessel, proceeding from a foreign port, is only passing through the territorial sea without entering internal waters.

ARTICLE 9
PAYMENT AND REMITTANCE

1. Revenues of shipping companies of one Contracting Party derived from international maritime transport in the other Contracting Party may be settled in freely convertible

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

or usable currencies, in accordance with the exchange regulations in force in the other Contracting Party.

2. The shipping companies of one Contracting Party shall have the right to use their income from the shipping services derived in the territory of the other Contracting Party towards shipping-related payments, in accordance with that other Contracting Party's laws, rules and regulations. Alternatively, the income may be transferred abroad in freely convertible or usable currencies, in accordance with the exchange regulations in force in that other Contracting Party.

ARTICLE 10
MARITIME COOPERATION

The Contracting Parties shall, with the aim of promoting the development of their maritime industry, subject to their respective laws, rules and regulations encourage their competent authorities, shipping companies, ports, relevant research institutions, colleges, universities and maritime education and training institutions to cooperate in, including but not limited to, the following fields:

a) exchange views on issues related to their maritime transport activities;
b) exchange information on legislation and regulations concerning maritime transport;
c) promote efficiency of transport service for international sea trade by effective administration of the ports and fleets of the Contracting Parties;
d) enhance maritime safety and marine environmental protection against pollution;
e) promote maritime education and training, especially the training of seafarers and instructors;
f) exchange personnel, and maritime technology;
g) promote cooperation to enhance maritime security, including the implementation of the provisions of the International Ship and Port Facility Security (ISPS) Code.

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

ARTICLE 11
MUTUAL CONSULTATION

1. Aiming at close cooperation in the effective implementation of this Agreement, and upon the request of any Member Country of ASEAN or China, representatives from the Contracting Parties may meet to discuss proposals submitted by either Contracting Party at the date and place mutually agreed upon. Such consultative meetings shall be held not later than 60 (sixty) days as from the date of the relevant proposal received.

2. The Ministry of Communications of China and the ASEAN Secretariat shall assist in convening the proposed consultative meetings.

ARTICLE 12
SETTLEMENT OF DISPUTES

Any dispute or differences arising out of the interpretation or implementation or application of the provisions of this Agreement shall be settled amicably through consultation or negotiation between the Contracting Parties.

ARTICLE 13
CONFIDENTIALITY

Any confidential information, document or data received pursuant to this Agreement shall not be disclosed or distributed to any third party, except to the extent authorised in written form to do so by the Contracting Party providing the information, document or data.

ARTICLE 14
ENTRY INTO FORCE, DURATION AND AMENDMENT

1. After the completion of its internal legal procedures for the entry into force of this Agreement, each Member Country

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

of ASEAN shall give written notification to the Secretary-General of ASEAN, who shall immediately notify China when all of the Member Countries of ASEAN have finished the said procedures.

2. After the completion of its internal legal procedures for the entry into force of this Agreement, China shall give written notification to the Secretary-General of ASEAN.

3. This Agreement shall enter into force upon the last written notification is received. The Secretary-General of ASEAN shall notify Member Countries of ASEAN of the entry into force of this Agreement.

4. This Agreement is concluded for a period of five years. It shall be tacitly renewed for successive periods of one year unless one of the Contracting Parties denounces it in writing six months before the date of expiry.

5. Each Contracting Party may request in writing any amendment of all or any part of this Agreement. Such amendment shall be mutually agreed upon in written form by the Contracting Parties and shall form an integral part of this Agreement. Such amendment shall enter into force immediately on such date as agreed upon in writing by the Contracting Parties.

ARTICLE 15
RELATION WITH EXISTING BILATERAL MARITIME TRANSPORT AGREEMENTS

If a provision in an existing bilateral agreement between an individual Member Country of ASEAN and China requires parties to extend to each other more favourable treatment than is required by the provisions of this Agreement, that provision shall prevail over this Agreement as between that individual Member Country of ASEAN and China. The provisions of this Agreement shall replace those of previous bilateral agreements concluded between Member Countries

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

of ASEAN and China, if the latter provisions are either inconsistent with the former, save for the situation referred to in the preceding sentence, or identical to them.

ARTICLE 16
PROTECTION OF NATIONAL SECURITY AND PUBLIC HEALTH

The provisions of this Agreement shall not limit the rights of any Member Country of ASEAN and China to take measures for the protection of its security and public health or prevention of disease and pests in animals and plants.

IN WITNESS WHEREOF the undersigned, duly authorised by the respective Governments of the ASEAN Member Countries and the Government of the People's Republic of China, have signed this Agreement.

DONE at **Singapore**, this **Second** Day of **November** in the year **Two Thousand and Seven**, in two original copies in the English Language.

For Member Countries of ASEAN, this Agreement shall be deposited with the Secretary-General of ASEAN who shall promptly furnish a certified true copy to all Member Countries of ASEAN.

For the Government of Brunei Darussalam:

....
PEHIN DATO ABU BAKAR APONG
Minister of Communications

For the Government of the People's Republic of China:

....
LI SHENGLIN
Minister of Communications

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For the Royal Government of Cambodia:

....
SUN CHANTHOL
Minister of Public Works and Transport

For the Government of the Republic of Indonesia:

....
JUSMAN SYAFII DJAMAL
Minister for Transportation

For the Government of the Lao People's Democratic Republic:

....
SOMMAD PHOLSENA
Minister of Communication, Transport, Post and Construction

For the Government of Malaysia:

....
DATO' SRI CHAN KONG CHOY
Minister of Transport

For the Government of the Union of Myanmar:

....
MAJ. GEN. THEIN SWE
Minister of Transport

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

For the Government of the Republic of Philippines:

....

GEN. LEANDRO R. MENDOZA (Ret.)
Secretary of Transportation and Communications

For the Government of the Republic of Singapore:

....

RAYMOND LIM
Minister for Transport

For the Royal Thai Government:

....

ADMIRAL THIRA HAO-CHAROEN
Minister of Transport

For the Government of the Socialist Republic of Viet Nam

....

DR. TRAN DOAN THO
Vice-Minister of Transport

CERTIFIED COPY
asean
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន
ស្តីពីការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ

....

បុព្វកថា

សមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា «រដ្ឋភាគី»

ដោយទទួលស្គាល់សារៈសំខាន់នៃការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ ដើម្បីគាំទ្រការធ្វើពាណិជ្ជកម្មយ៉ាងទូលំទូលាយ និងបង្កិតឲ្យជិតគ្នានូវសមាហរណកម្មសេដ្ឋកិច្ច

ដោយសម្គាល់ថា ប្រជាជាតិនានានៅក្នុងតំបន់ បានប្រកាន់យកជំហានទ្វេភាគី និង ពហុភាគីឆ្ពោះទៅរកការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ

ដោយរំលឹកឡើងវិញ ផែនការសកម្មភាពដឹកជញ្ជូនអាស៊ាន ឆ្នាំ២០០៥-២០១០ ដែលមានទិសដៅនយោបាយមួយ សំដៅប្រតិបត្តិកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់ ការដឹកជញ្ជូនអន្តររដ្ឋ និងការដឹកជញ្ជូនពហុរូបភាព ដើម្បីបង្កើតឡើងប្រព័ន្ធនៃការផ្គត់ផ្គង់ភស្តុភារ និងការដឹកជញ្ជូនមួយប្រកបដោយសមាហរណកម្ម និងប្រសិទ្ធភាព សម្រាប់ការធ្វើចរាចរណ៍ទំនិញ រវាងមូលដ្ឋានផ្គត់ផ្គង់ភស្តុភារ និងមជ្ឈមណ្ឌលពាណិជ្ជកម្មទាំងឡាយ នៅក្នុងរង្វង់ និងក្រៅរង្វង់អាស៊ាន

ដោយរំលឹកឡើងវិញផងដែរ កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅទីក្រុងហាណូយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ ដែលជាចំណងសម្ព័ន្ធរវាងគ្នា និងចែងឲ្យមានការដឹកជញ្ជូនអន្តររដ្ឋដែលមានការព្រមព្រៀងពីរដ្ឋភាគី

ដោយរំលឹកឡើងវិញបន្ថែម វាក្យខ័ណ្ឌទី៣ មាត្រា១នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន ដែលបានចុះហត្ថលេខានាថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩២ នៅសិង្ហបុរី ដែលចែងការអនុវត្តកិច្ចព្រមព្រៀងសេដ្ឋកិច្ច រដ្ឋសមាជិកពីរ ឬច្រើន អាចដំណើរការមុនបាន រដ្ឋជាសមាជិកផ្សេងទៀតដែលមិនទាន់បានរៀបចំរួចរាល់ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ

ដោយបំណងចង់បាន ការបង្កើតឡើងនូវប្រព័ន្ធដឹកជញ្ជូនក្នុងតំបន់មួយ ដែលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល សមាហរណកម្មរួមគ្នា និងសុខដុមនីយកម្ម ដែលបង្ហាញគ្រប់ទិដ្ឋភាពទាំងអស់នៃការដឹកជញ្ជូនអន្តររដ្ឋ

ដោយធានា ក្នុងការលើកទឹកចិត្ត និងសម្រួលដល់ការដឹកជញ្ជូនអន្តររដ្ឋក្នុងរង្វង់រដ្ឋភាគី

បានព្រមព្រៀងដូចខាងក្រោម៖

មាត្រា ១
គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

ក- សម្រួលដល់ការដឹកជញ្ជូនទំនិញអន្តររដ្ឋ រវាងនិងក្នុងរង្វង់រដ្ឋភាគី ដើម្បីគាំទ្រការអនុវត្តតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់បន្ថែមទៀត។

ខ- ធ្វើឲ្យការដឹកជញ្ជូន ការធ្វើពាណិជ្ជកម្ម និងបទប្បញ្ញត្តិគយ មានលក្ខណៈសាមញ្ញ និងសុខដុមនីយកម្ម និងតំរូវការទាំងឡាយសម្រាប់គោលបំណងនៃការសម្រួលការដឹកជញ្ជូនទំនិញអន្តររដ្ឋ។

គ- ធ្វើឲ្យការងារឆ្ពោះទៅរកការបង្កើតឡើងនូវប្រព័ន្ធនៃការដឹកជញ្ជូនមួយក្នុងតំបន់ ដែលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល សមាហរណ និងសុខដុមនីយកម្មនឹងគ្នា ដែលបង្ហាញគ្រប់ទិដ្ឋភាពទាំងអស់នៃការដឹកជញ្ជូនអន្តររដ្ឋ។

មាត្រា ២
គោលការណ៍

រដ្ឋភាគីក្រោមកិច្ចព្រមព្រៀង នឹងត្រូវបានណែនាំដោយគោលការណ៍ទាំងឡាយដូចខាងក្រោម៖

ក- ប្រព្រឹត្តកម្មជាតិនៃការអនុគ្រោះបំផុត៖ រដ្ឋភាគី ត្រូវយល់ព្រមអនុញ្ញាតឲ្យធ្វើការដឹកជញ្ជូនអន្តររដ្ឋរវាងទឹកដីនៃរដ្ឋភាគីនីមួយៗ តាមប្រព្រឹត្តិកម្មអនុគ្រោះ មិនតិចជាងប្រព្រឹត្តិកម្មដែលបានយល់ព្រមក្នុងការដឹកជញ្ជូនអន្តររដ្ឋ រវាងប្រទេសដទៃណាមួយផ្សេងទៀត។

ខ- សង្គតភាព៖ រដ្ឋភាគី ត្រូវធានាដល់ការអនុវត្តឲ្យមានសង្គតភាពនឹងគ្នានៃច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងការណែនាំខាងរដ្ឋបាល និងវិធានដទៃទៀត ជាមួយនឹងរដ្ឋភាគីនីមួយៗ។

គ- ធ្វើឲ្យមានលក្ខណៈសាមញ្ញ៖ រដ្ឋភាគី ត្រូវខំប្រឹងប្រែងធានាធ្វើឲ្យមានលក្ខណៈសាមញ្ញនូវរាល់នីតិវិធីនៃការដឹកជញ្ជូនអន្តររដ្ឋ និងតំរូវការរបស់អាស៊ាន។

ឃ- តម្លាភាព៖ រដ្ឋភាគី ត្រូវធ្វើរាល់ច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងការជូនដំណឹងខាងរដ្ឋបាលដែលពាក់ព័ន្ធទៅនឹងអាជ្ញាធរសាធារណៈក្នុងលក្ខណៈឆាប់រហ័ស តម្លាភាព រៀបរយ និងងាយស្រួលរកបាន។

ង- ប្រសិទ្ធភាព៖ រដ្ឋភាគី ត្រូវធានាឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខាងរដ្ឋបាលនៃការដឹកជញ្ជូនអន្តររដ្ឋ ដើម្បីសម្រួលចលនាទំនិញ ចូលទៅកាន់ និង/ឬចេញពីរដ្ឋភាគី។

ច- ការវិនិច្ឆ័យ៖ រដ្ឋភាគី ត្រូវធានាឲ្យមានយន្តការមួយដ៏មានប្រសិទ្ធភាពសម្រាប់ពិនិត្យមើលសេចក្តីសម្រេចនានារបស់អាជ្ញាធរពាក់ព័ន្ធនៃរដ្ឋភាគី ដែលអាចរកបាន និងងាយស្វែងរកសម្រាប់អ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់នៃការដឹកជញ្ជូនអន្តររដ្ឋនៅក្នុងអាស៊ាន។

ឆ- ការជួយឧបត្ថម្ភគ្នាទៅវិញទៅមក៖ រដ្ឋភាគី ត្រូវប្រឹងប្រែងក្នុងកិច្ចសហប្រតិបត្តិការឲ្យដល់ទីបំផុត និងជួយគ្នាទៅវិញទៅមករវាងទីភ្នាក់ងារដែលពាក់ព័ន្ធ ក្នុងការសម្រួលការដឹកជញ្ជូនទំនិញអន្តររដ្ឋក្នុងអាស៊ាន។

ផ្នែកទី ១
បញ្ញត្តិទូទៅ

មាត្រា ៣
និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

ក- «ការដឹកជញ្ជូនផ្ទៃក្នុងដោយប្រតិបត្តិករបរទេស» សំដៅដល់ការដឹកជញ្ជូនទំនិញដែលផ្ទុកឡើងក្នុងទឹកដីនៃរដ្ឋភាគីណាមួយ សម្រាប់ការផ្ទេរដាក់ចុះនៅកន្លែងណាមួយទៀត ក្នុងទឹកដីនៃរដ្ឋភាគីដូចគ្នា។

ខ- «អង្គភាពជាតិមានសមត្ថកិច្ច» សំដៅដល់អង្គភាពដែលរដ្ឋជាសមាជិកនីមួយៗ បានកំណត់សម្រាប់ការចុះបញ្ជីប្រតិបត្តិករដឹកជញ្ជូនអន្តររដ្ឋ។

គ- «ទំនិញមានគ្រោះថ្នាក់» សំដៅដល់វត្ថុធាតុទាំងឡាយ ដែលអាចមានឥទ្ធិពលប៉ះពាល់ដល់ផលប្រយោជន៍ខាងបរិស្ថាន សុខភាព សុវត្ថិភាព និងសន្តិសុខជាតិ។

ឃ- «រដ្ឋភាគីម្ចាស់ផ្ទះ» សំដៅដល់រដ្ឋភាគី ដែលនៅទីនោះត្រូវបានធ្វើការដឹកជញ្ជូន។

ង- «ការដឹកជញ្ជូនអន្តររដ្ឋ» សំដៅដល់ការដឹកជញ្ជូនទំនិញ និងការធ្វើចលនានៃមធ្យោបាយដឹកជញ្ជូន ចូលទៅ និង/ឬចេញពីរដ្ឋភាគី។

ច- «មធ្យោបាយដឹកជញ្ជូន» សំដៅដល់យានយន្តផ្លូវគោក រួមទាំងនាវាចម្លងយានយន្តផងដែរ។

ឆ- «ទំនិញងាយខូចខាត» សំដៅដល់ទំនិញដែលងាយខូច បាក់បែកនៅក្រោមឥទ្ធិពលនៃពេលវេលា សីតុណ្ហភាព ឬចលនាដឹកជញ្ជូន ប្រសិនបើវាមិនត្រូវបានគេដឹកនាំក្នុងស្ថានភាពល្អប្រសើរ។ ទំនិញទាំងអស់នេះ មានរាប់បញ្ចូលទាំងត្រីស្រស់ ឬត្រីដែលធ្វើឲ្យត្រជាក់ ឬ បង្កងសត្វទឹក ឬសត្វសមុទ្របង្កក ដែលមានសំបកក្រៅរឹងឬសិប្បីសត្វ ផ្លែឈើ បន្លែ ស៊ុត សាច់ជ្រូក និងផលិតផលធ្វើពីសាច់ជ្រូក។

ជ- «អគ្គលេខាធិការ» សំដៅដល់អគ្គលេខាធិការនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។

ញ- «ប្រតិបត្តិករដឹកជញ្ជូន» សំដៅដល់ម្ចាស់កម្មសិទ្ធ អ្នកបើកបរ និង/ឬ ភ្នាក់ងារនៃយានយន្តដឹកជញ្ជូនផ្លូវគោក ដែល៖

១- មានការអនុញ្ញាត ឬប័ណ្ណអនុញ្ញាតថ្នាក់ជាតិ សម្រាប់សេវាកម្មដឹកជញ្ជូនអន្តររដ្ឋ និងមានកំណត់ត្រាបញ្ជាក់អះអាងយល់ព្រមពីប្រទេសដើម តាមនីតិវិធីនៃការអនុញ្ញាត ឬប័ណ្ណអនុញ្ញាតរបស់ប្រទេសខ្លួន។

២- បានចុះបញ្ជីយ៉ាងត្រឹមត្រូវជាប្រតិបត្តិករដឹកជញ្ជូនអន្តររដ្ឋ ដោយអង្គភាពជាតិមានសមត្ថកិច្ច ឬគណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ ក្នុងរង្វង់រដ្ឋភាគី។

មាត្រា ៤
វិសាលភាពអនុវត្ត

បទបញ្ញត្តិដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តទៅលើរាល់ការដឹកជញ្ជូនអន្តររដ្ឋ។ កិច្ចព្រមព្រៀងនេះ មិនគ្របដណ្តប់លើការដឹកជញ្ជូនផ្ទៃក្នុងដោយប្រតិបត្តិករបរទេសទេ។

មាត្រា ៥
ការផ្តល់សិទ្ធិ

១- តាមករណីនីមួយៗដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ រដ្ឋភាគីនីមួយៗ ត្រូវផ្តល់សិទ្ធិទៅឲ្យរដ្ឋភាគីផ្សេងទៀត សម្រាប់ការដឹកជញ្ជូនអន្តររដ្ឋ ដោយៈ

ក- ការអនុញ្ញាតឲ្យប្រតិបត្តិករដឹកជញ្ជូន ដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវនៅក្នុងរដ្ឋភាគីមួយធ្វើការដឹកជញ្ជូនទំនិញ ចូលទៅ និង/ឬ ចេញពីរដ្ឋភាគីផ្សេងទៀត។

ខ- ផ្តល់សិទ្ធិក្នុងការផ្ទុក និងផ្ទេរទំនិញ ដែលដឹកឆ្ពោះទៅ ឬ ត្រឡប់។

២- រដ្ឋភាគីត្រូវខិតខំប្រឹងប្រែងផ្តល់នូវការសម្របសម្រួលដល់ការដឹកជញ្ជូនអន្តររដ្ឋ យោងតាមបទប្បញ្ញត្តិនៃកិច្ចព្រៀងនេះ។

៣- ការដឹកជញ្ជូនអន្តររដ្ឋ ត្រូវទៅតាមច្បាប់ និងវិធានដែលពាក់ព័ន្ធនៃរដ្ឋភាគីម្ចាស់ផ្ទះ ហើយមិនត្រូវដាក់ឲ្យនៅក្រោមកម្មវត្ថុក្នុងការពន្យារ ឬកំហិតលក្ខខ័ណ្ឌមិនចាំបាច់ណាមួយឡើយ។

ផ្នែកទី ២
ការកំណត់ផ្លូវដឹកជញ្ជូនអន្តររដ្ឋ និងច្រកទ្វារព្រំដែន

មាត្រា ៦
ការកំណត់ផ្លូវដឹកជញ្ជូនអន្តររដ្ឋ និងមធ្យាបាយបំពាក់នៃផ្លូវ

១- រដ្ឋភាគីយល់ព្រមថា តារាងបញ្ជីផ្លូវដឹកជញ្ជូនឆ្លងកាត់ដូចមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធនៃពិធីសារទី១ ស្តីពីការកំណត់ផ្លូវដឹកជញ្ជូនឆ្លងកាត់ និងមធ្យាបាយបំពាក់នៃផ្លូវនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅទីក្រុងបាងកក នាថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ត្រូវបានកំណត់ថាជាផ្លូវដឹកជញ្ជូនអន្តររដ្ឋ និងមធ្យាបាយបំពាក់ផ្លូវសម្រាប់បម្រើគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

២- រដ្ឋភាគីអាចផ្តួចផ្តើមសំណើសម្រាប់ការកែលំអ និង/ឬ ពង្រីកផ្លូវកំណត់ ការដឹកជញ្ជូនអន្តររដ្ឋ។ ការកែសម្រួល/ការផ្លាស់ប្តូរ ដែលបានលើកស្នើឡើងណាមួយ ដោយរដ្ឋភាគីមួយត្រូវទទួលបានការព្រមព្រៀងទៅវិញទៅមក ពីរដ្ឋភាគីមួយ ឬច្រើនដែលនៅជាប់គ្នា។ ការកែសម្រួលជាបន្តបន្ទាប់ណាមួយ ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអាស៊ាន។

៣- ដើម្បីសុវត្ថិភាព រដ្ឋភាគីត្រូវប្រឹងប្រែងផ្តល់ទីកន្លែងសម្រាប់ឈប់សម្រាក-សំចតយានយន្តនៅលើផ្លូវដែលបានកំណត់ នៅក្នុងអំឡុងពេលមួយសមរម្យ។

មាត្រា ៧
ប៉ុស្តិ៍ច្រកទ្វារព្រំដែន និងសម្ភារៈបំពាក់

១- រដ្ឋភាគីយល់ព្រមថា ប៉ុស្តិ៍ច្រកទ្វារព្រំដែនដែលមានបញ្ជាក់នៅក្នុងពិធីសារទី២ ស្តីពីការកំណត់ប៉ុស្តិ៍ច្រកទ្វារព្រំដែននៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលទំនិញឆ្លងកាត់ ត្រូវកំណត់ជាប៉ុស្តិ៍ច្រកទ្វារព្រំដែនសម្រាប់គោលបំណងដឹកជញ្ជូនអន្តររដ្ឋនៅក្រោមកិច្ចព្រមព្រៀងនេះ។

២- រដ្ឋភាគីអាចផ្តួចផ្តើមសំណើសម្រាប់ការកែលម្អ និង/ឬ ពង្រីកប៉ុស្តិ៍ច្រកទ្វារព្រំដែន ដែលបានកំណត់។ ការកែសម្រួល/ការផ្លាស់ប្តូរ ដែលបានលើកស្នើឡើងណាមួយ ដោយរដ្ឋភាគីមួយត្រូវទទួលបានការព្រមព្រៀងទៅវិញទៅមកពីរដ្ឋភាគីមួយ ឬច្រើននៅជាប់គ្នា។ ការកែសម្រួលជាបន្តបន្ទាប់ណាមួយ ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអាស៊ាន។

៣- រដ្ឋភាគីត្រូវផ្តល់ឲ្យនូវបរិក្ខារ និងទីតាំងពាក់ព័ន្ធឲ្យបានគ្រប់គ្រាន់ សម្រាប់ប៉ុស្តិ៍ច្រកទ្វារព្រំដែនតាមផ្លូវដឹកជញ្ជូនអន្តររដ្ឋ។

៤- រដ្ឋភាគីត្រូវខិតខំប្រឹងប្រែងដើម្បីៈ

ក- ផ្តល់ឲ្យនៅពេលណាមួយក៏ដោយ ដែលអាចធ្វើទៅបាន និងស្របទៅតាមយុត្តាធិការជាតិ ប៉ុស្តិ៍ច្រកទ្វារព្រំដែនដែលស្ថិតនៅជាប់គ្នាទៅនឹងប៉ុស្តិ៍ព្រំដែនទាំងឡាយនៃរដ្ឋភាគីដទៃដែលពាក់ព័ន្ធ ឲ្យមានតំបន់ត្រួតពិនិត្យរួមគ្នាជាមួយនឹងតម្រូវឲ្យមានការចែករំលែកការត្រួតពិនិត្យ ដើម្បីសម្របសម្រួលបែបបទឆ្លងដែន និងការត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូន និងទំនិញក្រោមកិច្ចព្រមព្រៀងនេះ ដើម្បីចៀសវាងការរើ និងការលើកផ្ទុកទំនិញចូលជាថ្មីម្តងទៀត។ ពុំមានអ្វីត្រូវរារាំងជំទាស់ដល់ដំណើរការដែលរដ្ឋភាគីពីរឬច្រើន ក្នុងការបង្កើតឡើងនូវការត្រួតពិនិត្យរួមគ្នាកន្លែងតែមួយ ដោយមន្ត្រីផ្លូវការនៃរដ្ឋភាគីទាំងឡាយនោះទេ។

ខ- ធានាថាត្រូវមានធនធានមនុស្សធ្វើការគ្រប់គ្រាន់សម្រាប់ជំរុញល្បឿននៃការបំពេញការងារ និងទម្រង់បែបបទ នីតិវិធីឆ្លងដែនឲ្យបានឆាប់រហ័ស ដូចជាការត្រួតពិនិត្យផ្នែកអន្តោប្រវេសន៍ គយនិងរដ្ឋាករ សុខាភិបាល និងការប្តូររូបិយបណ្ណបរទេស។

គ- សម្របសម្រួលម៉ោងធ្វើការរបស់ប៉ុស្តិ៍ដែលនៅជិតគ្នា។

ឃ- ផ្តល់ឲ្យទីណាមួយក៏ដោយ តាមតែអាចធ្វើទៅបាននូវទីលានសំចតគ្រប់គ្រាន់សម្រាប់កុងតេន័រនិងសម្រាប់យានយន្ត ដែលនៅរង់ចាំជម្រះទម្រង់បែបបទទំនិញ។

៥- រដ្ឋភាគីនីមួយៗ ទោះនៅទីណាក៏ដោយតាមតែអាចធ្វើទៅបាន យល់ព្រមអនុវត្តតាមមាត្រាទាំងឡាយនៃអនុសញ្ញាអន្តរជាតិស្តីពីការធ្វើសុខដុមនីយកម្មលើការត្រួតពិនិត្យទំនិញនៅតាមព្រំដែន ដែលបានចុះហត្ថលេខានៅទីក្រុងហ្សឺណែវ នាថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៨២ ក្នុងការខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យមានសុខដុមនឹងគ្នា តាមច្រកទ្វារព្រំដែនសម្រាប់ការដឹកជញ្ជូនទំនិញតាមកិច្ចព្រមព្រៀងនេះ។

ផ្នែកទី ៣
លក្ខខណ្ឌទូទៅសម្រាប់ការដឹកជញ្ជូនផ្លូវគោក

មាត្រា ៨
បទបញ្ជាចរាចរ

រដ្ឋភាគី ត្រូវតែខិតខំប្រឹងប្រែងរិះរកវិធានការឲ្យបានសមស្រប ដើម្បីធានានូវសុខដុមនីយកម្មខាងច្បាប់ចរាចរណ៍ផ្លូវគោក ដែលមានអានុភាពគតិយុត្តនៅក្នុងដែនដីរបស់ខ្លួន ដោយអនុលោមទៅតាមមាត្រាទាំងឡាយ ដែលមានចែងក្នុងអនុសញ្ញាស្តីពីចរាចរណ៍ផ្លូវគោក ដែលបានចុះហត្ថលេខានៅទីក្រុងវីយែន នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៦៨ និងអនុសញ្ញាស្តីពីផ្លាកសញ្ញា និងភ្លើងសញ្ញាផ្លូវគោកដែលបានចុះហត្ថលេខានៅក្រុងវីយែន នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៦៨។

មាត្រា ៩
សេវាកម្មដឹកជញ្ជូនអន្តររដ្ឋ

១- រដ្ឋភាគីនីមួយៗ ត្រូវអនុញ្ញាតឲ្យប្រើប្រាស់នូវមធ្យោបាយដឹកជញ្ជូនទាំងឡាយ ដែលបានចុះបញ្ជីនៅរដ្ឋភាគីដទៃផ្សេងទៀត ដើម្បីផ្តល់ឲ្យនូវសេវាកម្មដឹកជញ្ជូនអន្តររដ្ឋនៅលើដែនដី ដោយអនុលោមទៅតាមមាត្រា៥ នៃកិច្ចព្រមព្រៀងនេះ។

២- រដ្ឋភាគីយល់ព្រមថា បរិមាណយានយន្តដឹកជញ្ជូនអន្តររដ្ឋ ដែលអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់ការដឹកជញ្ជូនអន្តររដ្ឋមានចំនួនមិនលើសពី៥០០គ្រឿង ពីរដ្ឋភាគីនីមួយៗ។ នៅពេលបន្ទាប់មកទៀត បរិមាណយានយន្តដឹកជញ្ជូនអន្តររដ្ឋ គួរតែធ្វើការពិភាក្សាជាដំណាក់ៗតទៅទៀតរវាងរដ្ឋភាគី។

៣- លើកលែងតែបទប្បញ្ញត្តិដែលជាប់ទាក់ទងដល់បរិមាណយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ដូចដែលមានចែងក្នុងមាត្រា៤ នៃពិធីសារទី៣ ស្តីពីប្រភេទនិងបរិមាណយានយន្តផ្លូវគោក ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅទីក្រុងហាណូយ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ គោលការណ៍ទាំងឡាយដូចដែលបញ្ជាក់ក្នុងពិធីសារខាងលើ ត្រូវអនុវត្តដោយកិច្ចព្រមព្រៀងនេះ។

មាត្រា ១០
លិខិតអនុញ្ញាតការដឹកជញ្ជូនតាមផ្លូវគោក

រដ្ឋភាគីត្រូវទទួលរ៉ាប់រងធ្វើឲ្យសុខដុមនូវលិខិតអនុញ្ញាតដឹកជញ្ជូនតាមផ្លូវគោក ដែលជាតម្រូវការចាំបាច់ក្នុងការសម្រួលដល់ការដឹកជញ្ជូនអន្តររដ្ឋ។

មាត្រា ១១
តម្រូវការខាងបច្ចេកទេសសម្រាប់យានយន្ត

មធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការដឹកជញ្ជូនអន្តររដ្ឋ ត្រូវតែអនុលោមទៅតាមតម្រូវការខាងបច្ចេកទេស ដោយយោងទៅលើទំហំយានយន្ត ទម្ងន់យានយន្ត និងបន្ទុកទំនិញអតិបរមា ស្តង់ដារនៃការបញ្ចេញផ្សែង និងបញ្ហាផ្សេងៗដែលពាក់ព័ន្ធ ដូចមានបញ្ជាក់ក្នុងពិធីសារទី៨ ស្តីពីតម្រូវការខាងបច្ចេកទេសនៃយានយន្ត នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅទីក្រុងហាណូយ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨។

មាត្រា ១២
ការទទួលស្គាល់គ្នាទៅវិញទៅមកនូវវិញ្ញាបនប័ត្រត្រួតពិនិត្យយានយន្ត

១- រដ្ឋភាគី ត្រូវធ្វើការត្រួតពិនិត្យជាវដ្តចំពោះយានយន្តផ្លូវគោកទាំងឡាយ ដែលបានចុះបញ្ជីនៅក្នុងដែនដីរៀងៗខ្លួន និងដែលបានប្រើសម្រាប់ការដឹកជញ្ជូនអន្តររដ្ឋ។

២- រដ្ឋភាគីត្រូវទទួលស្គាល់វិញ្ញាបនបត្រត្រួតពិនិត្យជាវដ្តចំពោះយានយន្តផ្លូវគោកដែលបានប្រើប្រាស់សម្រាប់ការដឹកជញ្ជូនអន្តររដ្ឋ ដែលចេញដោយរដ្ឋភាគីដទៃទៀត ដោយស្របទៅតាមកិច្ចព្រមព្រៀង ស្តីពីការទទួលស្គាល់វិញ្ញាបនបត្រត្រួតពិនិត្យយានយន្តពាណិជ្ជកម្មសម្រាប់យានយន្តដឹកទំនិញ និងរថយន្តបំរើសេវាសាធារណៈ ដែលចេញឲ្យដោយប្រទេសជាសមាជិកអាស៊ាន ដែលបានចុះហត្ថលេខានៅសិង្ហបុរី ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៨។

មាត្រា ១៣
ការទទួលស្គាល់គ្នាទៅវិញទៅមកនូវប័ណ្ណបើកបរ

រដ្ឋភាគី ត្រូវទទួលស្គាល់ប័ណ្ណបើកបរក្នុងប្រទេសដែលចេញឲ្យដោយរដ្ឋភាគីដទៃទៀតសម្រាប់គោលបំណងនៃការដឹកជញ្ជូនអន្តររដ្ឋ ដោយស្របទៅតាមកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ប័ណ្ណបើកបរក្នុងប្រទេសដែលចេញឲ្យដោយបណ្តាប្រទេសអាស៊ាន ដែលបានចុះហត្ថលេខានៅទីក្រុងកូឡាឡាំពួរ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៨៥។

មាត្រា ១៤
គ្រោងការអាស៊ាននៃកាតព្វកិច្ចធានារ៉ាប់រងនៅលើយានយន្ត

១- យានយន្តផ្លូវគោក ដែលធ្វើដំណើរចូលទៅក្នុងដែនដីនៃរដ្ឋភាគីដទៃទៀត ត្រូវគោរពប្រតិបត្តិតាមកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលតម្រូវឲ្យមាននៅក្នុងរដ្ឋភាគីម្ចាស់ផ្ទះ។

២- រដ្ឋភាគីយល់ព្រមក្នុងការប្រតិបត្តិទៅតាមគ្រោងការនៃកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដូចដែលមានចែងក្នុងពិធីសារទី៥ ស្តីពីគ្រោងការអាស៊ានក្នុងកាតព្វកិច្ចធានារ៉ាប់រងយានយន្ត នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅទីក្រុងកូឡាឡាំពួរ កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០០១។

មាត្រា ១៥
កាតព្វកិច្ចនៃការបង់ប្រាក់ និងហិរញ្ញវត្ថុផ្សេងទៀត

រដ្ឋភាគីត្រូវខិតខំប្រឹងប្រែងមានលក្ខណៈសាមញ្ញ បង្រួបបង្រួមគ្នា និងសុខដុមនឹងគ្នានូវកាតព្វកិច្ចនៃការបង់ប្រាក់ និងហិរញ្ញវត្ថុផ្សេងទៀត ដែលត្រូវកំណត់ឲ្យបង់លើមធ្យោបាយយានយន្ត។

មាត្រា ១៦
ការនាំចូលយានយន្តជាបណ្តោះអាសន្ន

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ រដ្ឋភាគីត្រូវផ្តល់ឲ្យមានការនាំចូលជាបណ្តោះអាសន្ន យានយន្តផ្លូវគោក (និងប្រេងឥន្ធនៈ ដែលបានផ្ទុកក្នុងធុងប្រេងរបស់វា ប្រេងរំអិល គ្រឿងផ្គត់ផ្គង់សម្រាប់ថែទាំ និងគ្រឿងបន្លាស់ក្នុងចំនួនសមរម្យ) ដែលបានចុះបញ្ជីនៅក្នុងទឹកដីនៃរដ្ឋភាគីដទៃផ្សេងទៀត ដោយពុំមានការបង់ថ្លៃនូវអាករនាំចូល និងពន្ធនាំចូល ដោយពុំមានតម្កល់ទុកសំបុត្រធានារ៉ាប់រងគយ និងរួចផុតពីការហាមឃាត់ និងការដាក់កំហិតលក្ខខ័ណ្ឌទាំងឡាយសម្រាប់ការនាំចូល ហើយត្រូវជាកម្មវត្ថុនៃការនាំចេញត្រឡប់ទៅវិញ និងល័ក្ខខ័ណ្ឌពាក់ព័ន្ធផ្សេងទៀត។

ផ្នែកទី ៤
ការត្រួតពិនិត្យគយ អនាម័យ និងភូតគាមអនាម័យ

មាត្រា ១៧
នីតិវិធីគយប្រកបដោយភាពសុខដុម និងលក្ខណៈសាមញ្ញ

១- រដ្ឋភាគីត្រូវធ្វើឲ្យមានលក្ខណៈសាមញ្ញ និងនៅពេលណាក៏ដោយតាមដែលអាចធ្វើទៅបាន ប្រកបដោយភាពសុខដុមនូវនីតិវិធីត្រួតពិនិត្យគយ ក្នុងការដឹកជញ្ជូនអន្តររដ្ឋ ដើម្បីធានាឲ្យមានការប្រព្រឹត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិនានា ដែលគយគឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្ត។

២- រដ្ឋភាគី ត្រូវសម្របសម្រួលឲ្យមានការត្រួតពិនិត្យគយរួមគ្នា ទោះជានៅទីកន្លែងណាក៏ដោយ តាមតែអាចធ្វើទៅបាននូវការដឹកជញ្ជូនអន្តររដ្ឋ នៅចំណុចច្រកទ្វារព្រំដែននានា ដែលបានកំណត់។

មាត្រា ១៨
ការបង្កើតវិធានការអនាម័យ និងភូតគាមអនាម័យ

រដ្ឋភាគីត្រូវបង្កើតវិធានការអនាម័យ និងភូតគាមអនាម័យ ដូចដែលបានចែងនៅក្នុងពិធីសារទី៨ ស្តីពីអនាម័យ និងភូតគាមអនាម័យ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ដើម្បីសម្រួលការដឹកជញ្ជូនអន្តររដ្ឋ ចូលទៅក្នុងនិង/ឬចេញមកពីដែនដីរបស់គេទាំងអស់ និងធានាឲ្យមានការប្រព្រឹត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលអាជ្ញាធរពាក់ព័ន្ធជាអ្នកទទួលខុសត្រូវអនុវត្ត។

ផ្នែកទី ៥
បទប្បញ្ញត្តិផ្សេងទៀត

មាត្រា ១៩
បញ្ញត្តិពិសេសស្តីពីការដឹកជញ្ជូនអន្តររដ្ឋនូវទំនិញគ្រោះថ្នាក់

ការដឹកជញ្ជូនអន្តររដ្ឋនូវទំនិញដែលមានគ្រោះថ្នាក់នឹងមិនត្រូវបានគេអនុញ្ញាតទេ នៅក្រោមកិច្ចព្រមព្រៀងនេះ លើកលែងតែមានការអនុញ្ញាតពិសេសណាមួយពីរដ្ឋភាគី ដែលក្នុងទឹកដីរបស់គេទទួលយកការដឹកជញ្ជូនដូចនេះ ដូចដែលមានបញ្ជាក់ក្នុងពិធីសារទី៩ ស្តីពីទំនិញគ្រោះថ្នាក់ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅទីក្រុងហ្សាការតា កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២។

មាត្រា ២០
បញ្ញត្តិពិសេសស្តីពីការដឹកជញ្ជូនទំនិញហាមឃាត់ និង/ឬ ទំនិញជាប់កំហិត

ការដឹកជញ្ជូនអន្តររដ្ឋនូវទំនិញហាមឃាត់ ឬទំនិញជាប់កំហិត មិនស្ថិតនៅក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងនេះទេ។

មាត្រា ២១
បញ្ញត្តិពិសេសស្តីពីការដឹកជញ្ជូនអន្តររដ្ឋ នូវទំនិញងាយខូចខាត

តាមករណីបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ រដ្ឋភាគីត្រូវខិតខំប្រឹងប្រែងសម្របសម្រួលដល់ការដឹកជញ្ជូនអន្តររដ្ឋនូវទំនិញដែលងាយខូចខាត។

មាត្រា ២២
បញ្ញត្តិនៃការបម្រុងទុក

កិច្ចព្រមព្រៀងនេះ មិនតម្រូវឲ្យធ្វើតាមវិធីណាមួយ ក្នុងការបម្រុងទុក ដែលបានចែងក្នុងកិច្ចព្រមព្រៀងនេះទេ ដរាបណាពេលវេលា និងលក្ខខណ្ឌ ដែលស្របទៅតាមគោលការណ៍ទាំងឡាយដែលលេចជារូបរាងឡើងក្នុងកិច្ចព្រមព្រៀងនេះ។ កិច្ចព្រមព្រៀងនេះ មិនតម្រូវឲ្យបម្រុងទុកដែលអាចនឹងយល់ព្រមឡើងរវាងរដ្ឋភាគីក្នុងពេលអនាគត។

មាត្រា ២៣
ច្បាប់ជាតិ

១- លើកលែងតែមានបទប្បញ្ញត្តិផ្សេងចែងដោយកិច្ចព្រមព្រៀងនេះ ច្បាប់ និងបទប្បញ្ញត្តិខាងក្នុងប្រទេសទាំងឡាយនៃរដ្ឋភាគីដែលទាក់ទងទៅនឹងការដឹកជញ្ជូនទំនិញ ត្រូវអនុវត្តដោយស្មើភាពគ្នា និងដោយគ្មានការរើសអើង ក្នុងការដឹកជញ្ជូនអន្តរដ្ឋ។

២- រដ្ឋភាគី ត្រូវខិតខំប្រឹងប្រែងធ្វើសុខដុមនឹងគ្នា និងធ្វើឲ្យសាមញ្ញនូវច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរដ្ឋបាលទាំងឡាយ ដែលជាប់ពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនអន្តរដ្ឋ ដោយអនុលោមទៅតាមបទប្បញ្ញត្តិដែលចែងក្នុងកិច្ចព្រមព្រៀងនេះ។

មាត្រា ២៤
ការអនុវត្តច្បាប់ជាតិ

លើកលែងតែមានចែងនៅកន្លែងណាមួយផ្សេង នៅក្នុងកិច្ចព្រមព្រៀងរវាងរដ្ឋភាគី រាប់បញ្ចូលទាំងកិច្ចព្រមព្រៀងនេះ៖

ក- មធ្យោបាយដឹកជញ្ជូននៃរដ្ឋភាគីមួយ ដោយរាប់ទាំងមនុស្ស និងទំនិញ ត្រូវអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋភាគីនោះ ដែលកំពុងអនុវត្តជាធរមាន នៅក្នុងទឹកដីរបស់ខ្លួន។

ខ- រដ្ឋភាគីណាមួយក៏ដោយ មិនត្រូវដាក់ការបង្ខំលើមនុស្ស ឬទំនិញទាំងឡាយនៃរដ្ឋភាគីដទៃទៅតាមតម្រូវការដែលមានកំហិតលក្ខខណ្ឌច្រើនជាងលក្ខខណ្ឌដែលមាននោះក្នុងច្បាប់និងបទប្បញ្ញត្តិ ទាក់ទងមធ្យោបាយដឹកជញ្ជូនរបស់ខ្លួនទេ។

គ- រដ្ឋភាគីម្ចាស់ផ្ទះ អាចបដិសេធជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ការឆ្លងចូលទៅក្នុងទឹកដីរបស់ខ្លួននូវមនុស្ស អ្នកបើកបរ ប្រតិបត្តិករដឹកជញ្ជូន មធ្យោបាយដឹកជញ្ជូន ដែលបានរំលោភច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ឬក៏កិច្ចព្រមព្រៀងនេះ។

មាត្រា ២៥
តម្លាភាព

១- រដ្ឋភាគី ត្រូវធានាឲ្យមានតម្លាភាពនៃការគោរពច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរដ្ឋបាលរបស់ខ្លួន ដែលមានអានុភាពលើការសម្របសម្រួលនៃការដឹកជញ្ជូនទំនិញអន្តររដ្ឋ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ និងពិធីសារ។

២- សម្រាប់គោលបំណងនេះ រាល់រដ្ឋភាគីទាំងអស់ ត្រូវតែម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន នូវច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរដ្ឋបាល ដែលបានបំពេញបែបបទរៀងៗខ្លួនរួច មិនឲ្យលើសពីរយៈពេល៦ខែ បន្ទាប់ពីកិច្ចព្រមព្រៀងនេះបានចូលជាធរមាន។

៣- ប្រសិនបើឯកសារទាំងឡាយនេះ មិនមែនជាភាសាអង់គ្លេស រដ្ឋភាគីនោះត្រូវតែម្កល់ទុកនូវការបកប្រែឯកសារទាំងនោះជាភាសាអង់គ្លេស នៅក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។

មាត្រា ២៦
កិច្ចសង្គ្រោះក្នុងគ្រោះថ្នាក់ចរាចរ

នៅពេលដែលមានមធ្យោបាយដឹកជញ្ជូន ដោយរាប់បញ្ចូលទាំងមនុស្ស និងទំនិញនៃរដ្ឋភាគីមួយ ដែលបានជាប់ពាក់ព័ន្ធក្នុងគ្រោះថ្នាក់ចរាចរ នៅក្នុងទឹកដីនៃរដ្ឋភាគីដទៃ រដ្ឋភាគីនោះភ្លាមៗត្រូវផ្តល់ឲ្យនូវកិច្ចជួយសង្គ្រោះដែលអាចធ្វើទៅបានចំពោះមធ្យោបាយដឹកជញ្ជូន ដោយរាប់បញ្ចូលទាំងមនុស្ស និងទំនិញ និងជូនដំណឹងដល់អាជ្ញាធរនៃរដ្ឋភាគីឲ្យបានសមស្រប ដែលមានការពាក់ព័ន្ធឲ្យបានឆាប់រហ័សជាទីបំផុត តាមតែអាចធ្វើទៅបាន។

ផ្នែកទី ៦
ការរៀបចំស្ថាប័ន

មាត្រា ២៧
ការរៀបចំស្ថាប័ន

១- គណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ ដែលបានបង្កើតឡើងយោងតាមមាត្រា២៩នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខា នៅទីក្រុងហាណូយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ ត្រូវទទួលខុសត្រូវផងដែរសម្រាប់ការសម្របសម្រួល និងអនុវត្តកិច្ចព្រមព្រៀងនេះ។

២- ក្រុមប្រឹក្សាសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ ដែលបានបង្កើតឡើងយោងតាមមាត្រា២៩នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខា នៅទីក្រុងហាណូយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ មានតួនាទីក្នុងការសម្របសម្រួល និងការអនុវត្តទាំងស្រុងនៃកិច្ចព្រមព្រៀងនេះ។ ក្រុមប្រឹក្សានេះ អាចអញ្ជើញនិងស្វែងរកជំនួយ

ពីមន្ត្រី-ស្ថាប័នសម្របសម្រួលផ្សេងទៀតរបស់អាស៊ាន សម្រាប់រាល់គ្រប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។

៣- ក្រុមប្រឹក្សាសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ ត្រូវធ្វើរបាយការណ៍ជាដំណាក់ៗលើការអនុវត្តកិច្ចព្រមព្រៀងនេះ និងស្វែងរកការណែនាំសមរម្យលើបញ្ហាសំខាន់ៗជាចាំបាច់ពីថ្នាក់រដ្ឋមន្ត្រីអាស៊ានផ្សេងទៀត ដែលពាក់ព័ន្ធ។

៤- លេខាធិការដ្ឋានអាស៊ាន ត្រូវជួយដល់ក្រុមប្រឹក្សាសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ ក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀងនេះ និងជាពិសេសនៅក្នុងការតាមដានត្រួតពិនិត្យ និងធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះ។ លេខាធិការដ្ឋានអាស៊ាន ត្រូវដាក់ស្នើរបាយការណ៍វាយតម្លៃជូនទៅក្រុមប្រឹក្សាសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់សម្រាប់សកម្មភាពបន្ថែមទៀត។

ផ្នែកទី ៧
អវសានប្បញ្ញត្តិ

មាត្រា ២៨
ការដោះស្រាយវិវាទ

បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងពិធីសារអាស៊ានស្តីពីយន្តការដោះស្រាយការវិវាទ ដែលធ្វើឡើងនៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ និងការធ្វើវិសោធនកម្មជាបន្តបន្ទាប់មកទៀត ត្រូវបានអនុវត្តដើម្បីដោះស្រាយវិវាទ ដែលកើតឡើងនៅក្រោមកិច្ចព្រមព្រៀងនេះ។

មាត្រា ២៩
កិច្ចព្រមព្រៀងដទៃនៅតែមានអានុភាពគតិយុត្ត

កិច្ចព្រមព្រៀងនេះ ឬសកម្មភាពខ្លះៗដែលនៅក្នុងកិច្ចព្រមព្រៀងនេះ ពុំមានអានុភាពលើសិទ្ធិ និងកាតព្វកិច្ចនៃរដ្ឋភាគី នៅក្រោមកិច្ចព្រមព្រៀងខ្លះៗ ដែលមានអត្ថិភាពរួចមកហើយ ឬអនុសញ្ញាអន្តរជាតិទាំងឡាយ ដែលខ្លួនជារដ្ឋភាគីផងដែរ។

មាត្រា ៣០
ការរៀបចំកិច្ចប្រតិបត្តិ

១- នៅក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ រដ្ឋភាគីពីរ ឬច្រើន ដែលបានរៀបចំខ្លួនរួចរាល់ហើយ អាចធ្វើការចរចារ និងចុះហត្ថលេខាការអនុវត្តកិច្ចព្រមព្រៀង ឬចំណាត់ការដែលស្របទៅតាមរូបមន្តអាស៊ានដកអ៊ិច (ASEAN-X) ដោយឈរលើមូលដ្ឋានភាគីច្រើន ឬពហុភាគី ឬអនុតំបន់។ រដ្ឋភាគីដទៃទៀត អាចចូលរួមក្នុងការអនុវត្តបាននៅពេលណាដែលពួកគេរៀបចំខ្លួនរួចរាល់។

២- ពិធីសារទាំងឡាយនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់ ដែលបានយោងសម្រាប់អនុវត្តនៅក្រោមកិច្ចព្រមព្រៀងនេះ និងវិសោធនកម្មណាមួយនៃពិធីសារទាំងនេះ ត្រូវអនុវត្តទៅតាមការកែសម្រួលជាចាំបាច់ទាំងឡាយសម្រាប់ការដឹកជញ្ជូនអន្តររដ្ឋ នៅក្រោមកិច្ចព្រមព្រៀងនេះ។ ពិធីសារទាំងនេះ និងវិសោធនកម្មណាមួយរបស់វាជាបន្ទាប់មកទៀត ត្រូវចាត់ទុកថាជាផ្នែករួមបញ្ចូលគ្នានៃកិច្ចព្រមព្រៀងនេះ។

៣- ដោយគោរពតាមរដ្ឋភាគីនីមួយៗ ប្រសិទ្ធភាពនៃពិធីសារទាំងនោះ សម្រាប់កិច្ចព្រមព្រៀងនេះ ត្រូវគិតចាប់ផ្តើមពីពេលនៃការតម្កល់ទុកលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រមនៃពិធីសារទាំងនោះ ឬកាលបរិច្ឆេទនៃការតម្កល់ទុកលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រមនៃកិច្ចព្រមព្រៀងនេះ នៅអគ្គលេខាធិការអាស៊ាន ចំពោះឯកសារណាមួយដែលបានតម្កល់ជាចុងក្រោយ។

មាត្រា ៣១
អវសានប្បញ្ញត្តិ

១- កិច្ចព្រមព្រៀងនេះ ជាកម្មវត្ថុក្នុងការផ្តល់សច្ចាប័ន ឬការយល់ព្រមចូលដោយរដ្ឋភាគី។

២- លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រមចូលត្រូវតម្កល់ទុកនៅអគ្គលេខាធិការអាស៊ាន ដែលជាអ្នកបញ្ជូនយ៉ាងរហ័ស ទៅរដ្ឋភាគីនីមួយៗនូវការតម្កល់ទុកនេះ។

៣- កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានរយៈពេល៣០ថ្ងៃ បន្ទាប់ពីការតម្កល់ទុកជាបន្ទាប់លំដាប់ទី២ នូវលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រមចូល និងត្រូវមានប្រសិទ្ធភាពត្រឹមតែក្នុងរង្វង់រដ្ឋភាគីដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមចូលនៃកិច្ចព្រមព្រៀងនេះ។ សម្រាប់រដ្ឋភាគី ក្នុងការផ្តល់សច្ចាប័ន ឬការយល់ព្រមចូលលើកិច្ចព្រមព្រៀងនេះ នៅក្រោយពេលពីការតម្កល់ទុកនូវលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រមចូលជាលំដាប់ទី២ នោះ កិច្ចព្រមព្រៀងនេះ នឹងត្រូវចូលជាធរមានក្នុងរយៈពេល៣០ថ្ងៃដែរ នៅបន្ទាប់ពីការតម្កល់ទុកនៃរដ្ឋភាគីនោះ នូវលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ឬការយល់ព្រមនោះ។

៤- គ្មានល័ក្ខខ័ណ្ឌបម្រុងទុកជាមុនទេ អាចត្រូវធ្វើឡើងទៅលើកិច្ចព្រមព្រៀងនេះបាន ទោះជានៅពេលដែលចុះហត្ថលេខា និងនៅពេលផ្តល់សច្ចាប័ន ឬការយល់ព្រមចូលរួចហើយក៏ដោយ។

៥- ការធ្វើវិសោធនកម្មណាមួយនៃបទប្បញ្ញត្តិក្នុងកិច្ចព្រមព្រៀងនេះ មានអានុភាពទៅបានដោយមានការយល់ព្រមនៃរដ្ឋភាគីទាំងអស់។

ដើម្បីជាសក្ខីភាពតទៅមុខ ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធិប្រទានយ៉ាងត្រឹមត្រូវពីរដ្ឋាភិបាលរៀងខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ។

ធ្វើនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ ជាច្បាប់ចម្លងតែមួយគត់ជាភាសាអង់គ្លេស។

តំណាងឲ្យប្រ៊ុយណេដារូសាឡាំ

PEHIN DATO ABU BAKAR APONG
រដ្ឋមន្ត្រីគមនាគមន៍

តំណាងឲ្យព្រះរាជាណាចក្រកម្ពុជា

TAUCH CHANKOSAL
រដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន

តំណាងឲ្យសាធារណរដ្ឋឥណ្ឌូណេស៊ី

JUSMAN SYAFII DJAMAL
រដ្ឋមន្ត្រីគមនាគមន៍

តំណាងឲ្យសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

SOMMAD PHOLSENA
រដ្ឋមន្ត្រីសាធារណការនិងដឹកជញ្ជូន

តំណាងឲ្យម៉ាឡេស៊ី

DATUK ONG TEE KEAT
រដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងឲ្យសហភាពមីយ៉ាន់ម៉ា

MAJOR GENERAL THEIN SWE
រដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងឲ្យសាធារណរដ្ឋហ្វីលីពីន

GEN.LEANDRO R.MENDOZA(Ret.)

រដ្ឋមន្ត្រីដឹកជញ្ជូន និងគមនាគមន៍

តំណាងសាធារណរដ្ឋសិង្ហបុរី

RAYMOND LIM
រដ្ឋមន្ត្រីគមនាគមន៍ និងបច្ចេកវិជ្ជាព័ត៌មាន

តំណាងឲ្យព្រះរាជាណាចក្រថៃ

SOPHON ZARAM
រដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងឲ្យសាធារណរដ្ឋសង្គមនិយមវៀតណាម

HO NGHIA DUNG
រដ្ឋមន្ត្រីដឹកជញ្ជូន

ASEAN FRAMEWORK AGREEMENT ON THE FACILITATION OF INTER-STATE TRANSPORT

PREAMBLE

The Members of the Association of Southeast Asian Nations (hereinafter referred to as **Contracting Parties**);

RECOGNISING the importance of facilitating inter-state transport of goods to support greater trade and bring about closer economic integration;

NOTING that nations in the region have taken steps bilaterally and multilaterally to facilitate inter-state transport;

RECALLING ASEAN Transport Action Plan 2005-2010 with a policy direction to operationalise the ASEAN Framework Agreements on the Facilitation of Goods in Transit, Inter-State Transport and Multimodal Transport in order to create an integrated and efficient logistics and multimodal transportation system for cargo movement between logistics bases and trade centers within and beyond ASEAN,

RECALLING also the ASEAN Framework Agreement on the Facilitation of Goods in Transit signed in Ha Noi on 16 December 1998 which, inter alia, provides for inter-state transport to be agreed upon by all Contracting Parties;

RECALLING further paragraph 3 of Article I of the Framework Agreement on Enhancing ASEAN Economic Cooperation signed on 28 January 1992 in Singapore, that in the implementation of economic arrangements, two or more Member Countries may proceed first if other Member Countries are not ready to implement these arrangements;

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

DESIRING to establish an effective, efficient, integrated and harmonised regional transport system that addresses all aspects of inter-state transport;

UNDERTAKING to encourage and facilitate inter-state traffic among the Contracting Parties;

HAVE AGREED AS FOLLOWS:

Article 1
Objectives

The objectives of this Agreement are:

a) to facilitate inter-state transport of goods between and among the Contracting Parties, to support the implementation of the ASEAN Free Trade Area, and to further integrate the region's economies;

b) to simplify and harmonise transport, trade and customs regulations and requirements for the purpose of facilitation of inter-state transport of goods; and

c) to work in concert towards establishing an effective, efficient, integrated and harmonised regional transport system that addresses all aspects of inter-state transport.

Article 2
Principles

The Contracting Parties shall be guided by the following principles under this Agreement:

a) Most Favoured Nation Treatment: Contracting Parties shall accord to inter-state transport between the territories of any other Contracting Parties treatment no less favourable than the treatment accorded to inter-state transport between any other country;

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

b) Consistency: Contracting Parties shall ensure the consistent application of the relevant laws and regulations, procedures, and administration guidelines and other rulings within each Contracting Party;

c) Simplicity: Contracting Parties shall endeavour to ensure the simplification of all inter-state transport procedures and requirements in ASEAN;

d) Transparency: Contracting Parties shall make all laws, regulations, procedures and administrative notifications pertaining to the relevant authorities publicly available in a prompt, transparent and readily accessible manner;

e) Efficiency: Contracting Parties shall ensure the efficient and effective administration of inter-state transport to facilitate the movement of goods into and/or from the Contracting Parties;

f) Appeals: Contracting Parties shall ensure that an effective mechanism for the review of the decisions by the relevant authorities of Contracting Parties is made available and accessible to users and providers of inter-state transport within ASEAN; and

g) Mutual Assistance: Contracting Parties shall endeavour their utmost cooperation and mutual assistance between the concerned agencies involved in the facilitation of inter-state transport in ASEAN.

PART I
GENERAL PROVISIONS

Article 3
Definitions

For the purposes of this Agreement:

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

(a) "Cabotage" means the carriage of goods loaded in the territory of a Contracting Party for unloading at a place within the territory of the same Contracting Party;

(b) "Competent National Body" means the body designated by each Member Country for the registration of inter-state transport operators;

(c) "Dangerous goods" means those substances and articles which may affect the interest of environment, health, safety and national security;

(d) "Host Contracting Party" means the Contracting Party where transport is performed;

(e) "Inter-state transport" means transport of goods and the movement of means of transport into and/or from Contracting Parties;

(f) "Means of transport" means road vehicles, including those on-board roll-on/roll-off vessels;

(g) "Perishable goods" means goods that are easily damaged under the influence of time, temperature or transport movement if they are not carried in good condition. These may include fresh, chilled or frozen fish, crustacean, molluscs, fruits, vegetables, chilled or frozen meat or poultry, dairy and dairy products, eggs and egg products, and swine and pork products ;

(h) "Secretary-General" means Secretary-General of the Association of Southeast Asian Nations, and

(i) "Transport Operator" means owners, drivers, and/or agents of road transport vehicles who i) have the appropriate national permit or license to operate inter-state transport services and who have a proven compliance record to the rules and procedures under said permit or license; and ii) are duly registered as inter-

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

state transport operators by the respective Competent National Body or the National Transit Transport Coordinating Committee (NTTCC) among the Contracting Parties.

Article 4
Scope of Application

The provisions of this Agreement shall apply to inter-state transport. Cabotage is not covered by this Agreement.

Article 5
Grant of Rights

1. Subject to the provisions of this Agreement, each Contracting Party shall grant to other Contracting Parties the right to inter-state transport by:

   a) allowing transport operators duly established in one Contracting Party to undertake transport of goods into and/or from the territories of other Contracting Parties; and

   b) granting the right to load and discharge goods destined for or coming from Contracting Parties.

2. The Contracting Parties shall endeavour to provide facilities for inter-state transport in accordance with the provisions of this Agreement.

3. Inter-state transport, provided that it complies with the relevant laws and rules of the host Contracting Party, shall not be subject to any unnecessary delays or restrictions.

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

PART II
DESIGNATION OF INTER-STATE TRANSPORT ROUTES AND FRONTIER POSTS

Article 6
Inter-State Transport Routes and Facilities

1. The Contracting Parties agree that the list* of transit transport routes as specified in the Annex of Protocol 1: Designation of Transit Transport Routes and Facilities, under the ASEAN Framework Agreement on Facilitation of Goods in Transit, signed at Bangkok on 8 February 2007, shall be the designated inter-state transport routes and facilities for the purpose of this Agreement.

2. The Contracting Parties may initiate proposals for the modifications and/or expansion of the designated inter-state transport routes from time to time. Any proposed modifications/changes by one Contracting Party shall be with the mutual agreement of the immediate neighbouring Contracting Party or Parties. Subsequent amendments shall be deposited with the Secretary-General of ASEAN.

3. For the benefit of safety, the Contracting Parties shall endeavour to provide in their territories vehicle rest areas on these designated routes at appropriate intervals.

Article 7
Frontier Posts and Facilities

1. The Contracting Parties agree that the frontier posts as specified in Protocol 2: Designation of Frontier Posts, under the ASEAN Framework Agreement on Facilitation of Goods in Transit, shall be the designated frontier posts for the purpose of inter-state transport under this Agreement.

2. The Contracting Parties may initiate proposals for the modifications and/or expansion of the designated frontier posts from time to time. Any proposed modifications/changes by one

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

Contracting Party shall be with the mutual agreement of the immediate neighbouring Contracting Party or Parties. Subsequent amendments shall be deposited with the Secretary-General of ASEAN.

3. The Contracting Parties shall provide adequate facilities and related installations at frontier posts over the inter-state transport routes.

4. The Contracting Parties shall endeavour to:

(a) Provide, whenever possible, and within their national jurisdiction, frontier posts which are physically adjacent to those of other Contracting Parties concerned with control areas with checking requirements in order to facilitate the clearance and examination of the means of transport and goods under this Agreement, so that repeated unloading and reloading of these goods may be avoided. Nothing shall prevent two or more Contracting Parties from conducting joint examination at the same place by officials of these Contracting Parties;

(b) Ensure that adequate manpower resources are made available for the speedy completion and clearance of frontier formalities, such as immigration, customs, health and foreign exchange controls;

(c) Coordinate working hours of adjacent posts; and

(d) Provide, wherever possible, adequate parking space for containers and for vehicles awaiting goods clearance.

5. The Contracting Parties agree to be guided, wherever possible, by the provisions of the International Convention on Harmonization of Frontier Control of Goods, signed at Geneva on 21 October 1982, in their efforts to harmonise frontier facilities for goods transported under this Agreement.

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

PART III
GENERAL CONDITIONS FOR ROAD TRANSPORT

Article 8
Traffic Regulations

The Contracting Parties shall endeavour to take appropriate measures to ensure the harmonisation of road traffic regulations in force in their territories conform in substance to the provisions of the Convention on Road Traffic, signed at Vienna on 8 November 1968, and the Convention on Road Sign and Signals, signed at Vienna on 8 November 1968.

Article 9
Inter-State Transport Services

1. Each Contracting Party shall allow the use of means of transport registered in other Contracting Parties to provide inter-state transport services on its territory in accordance with Article 5 of this Agreement.

2. The Contracting Parties agree that the number of inter-state transport vehicles allowed to be used for inter-state transport shall be no more than five hundred (500) vehicles per Contracting Party. Thereafter, the number of inter-state transport vehicles shall be discussed from time to time between the Contracting Parties.

3. Except for the provisions relating to the number of road transit transport vehicles as provided for in Article 4 of Protocol 3: Types and Quantity of Road Vehicles, under the ASEAN Framework Agreement on Facilitation of Goods in Transit, signed at Ha Noi on 15 September 1999, the principles as specified in the said Protocol shall apply to this Agreement.

Article 10
Road Transport Permits

The Contracting Parties undertake to harmonise road transport permit requirements in order to facilitate inter-state transport.

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

Article 11
Technical Requirements of Road Vehicles

Means of transport used in inter-state transport shall conform to the technical requirements regarding vehicle dimensions, maximum weights and loads, emission standards and related matters as specified in Protocol 4: Technical Requirements of Vehicles, under the ASEAN Framework Agreement on the Facilitation of Goods in Transit, signed at Ha Noi on 15 September 1999.

Article 12
Mutual Recognition of Inspection Certificates

1. The Contracting Parties undertake to institute periodic inspection of road vehicles registered in their respective territories and used for inter-state transport.

2. The Contracting Parties shall recognise periodic inspection certificates of road vehicles used for inter-state transport issued by the other Contracting Parties, in accordance with the Agreement on the Recognition of Commercial Vehicle Inspection Certificates for Goods Vehicles and Public Services Vehicles Issued by ASEAN Member Countries signed at Singapore on 10 September 1998.

Article 13
Mutual Recognition of Driving Licenses

The Contracting Parties shall recognise domestic driving licenses issued by all other Contracting Parties for the purpose of inter-state transport in accordance with the Agreement on the Recognition of Domestic Driving Licenses Issued by ASEAN Countries signed at Kuala Lumpur on 9 July 1985.

Article 14
ASEAN Scheme of Compulsory Motor Vehicle Insurance

1. Motor vehicles travelling to the territory of other Contracting Parties shall comply with the compulsory motor vehicle insurance required in the host Contracting Party.

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

2. The Contracting Parties agree to conform to the scheme of compulsory motor vehicle insurance as specified in Protocol 5: ASEAN Scheme of Compulsory Motor Vehicle Insurance, under the ASEAN Framework Agreement on the Facilitation of Goods in Transit, signed at Kuala Lumpur on 8 April 2001.

Article 15
Charges and Other Financial Obligations

The Contracting Parties shall endeavour to simplify, consolidate and harmonise charges and other financial obligations which are levied on the means of transport.

Article 16
Temporary Admission of Road Vehicles

For the purpose of this Agreement, the Contracting Parties shall grant temporary admission to road vehicles (and the fuel contained in its supply tanks, its lubricants, maintenance supplies, and spare parts in reasonable quantities) registered in the territory of another Contracting Party, without payment of import duties and import taxes, without depositing a Customs' guarantee bond and free of import prohibitions and restrictions, subject to re-exportation and other related conditions.

PART IV
CUSTOMS CONTROL, SANITARY AND PHYTOSANITARY MEASURES

Article 17
Harmonisation and Simplification of Customs Procedures

1. The Contracting Parties shall simplify and whenever possible harmonise the customs control procedures of inter-state transport to ensure compliance with the laws and regulations which the Customs are responsible for enforcing.

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

2. The Contracting Parties shall facilitate joint customs inspection, wherever possible, of inter-state transport at their designated frontier points.

Article 18
Establishment of Sanitary and Phytosanitary Measures

The Contracting Parties agree to establish sanitary and phytosanitary measures as specified in Protocol 8: Sanitary and Phytosanitary Measures, under the ASEAN Framework Agreement on the Facilitation of Goods in Transit, signed at Phnom Penh on 27 October 2000, to facilitate inter-state transport of goods into and/or from their territories and ensure compliance with the laws and regulations which the relevant authorities are responsible for enforcing.

PART V
MISCELLANEOUS PROVISIONS

Article 19
Special Provisions on
Inter-State Transport of Dangerous Goods

The Inter-State Transport of Dangerous Goods shall not be permitted under this Agreement, unless there is a special permit of the Contracting Party in whose territory the transport is undertaken, as specified in Protocol 9: Dangerous Goods, under the ASEAN Framework Agreement on the Facilitation of Goods in Transit, signed at Jakarta on 20 September 2002.

Article 20
Special Provisions on
Transport of Prohibited and/or Restricted Goods

The Inter-State Transport of prohibited and/or restricted goods shall not be permitted under this Agreement.

CERTIFIED COPY
DEPUTY SECRETARY-GENERAL, THE ASEAN SECRETARIAT
asean

Article 21
Special Provisions on Inter-State Transport of Perishable Goods

Subject to the provisions of this Agreement, the Contracting Parties shall endeavour to facilitate inter-state transport of perishable goods.

Article 22
Provision of Greater Facilities

This Agreement does not entail in any way the withdrawal of facilities which are greater than those provided for in this Agreement as long as the terms and conditions are consistent with the principles embodied in this Agreement. This Agreement also does not preclude the granting of greater facilities which may be agreed between Contracting Parties in the future.

Article 23
Domestic Legislation

1. Unless otherwise provided for by this Agreement, the domestic laws and regulations of the Contracting Parties relating to transport of goods, shall apply equally and without discrimination to inter-state transport.

2. The Contracting Parties shall endeavour to harmonise and simplify their rules, regulations and administrative procedures relating to inter-state transport in accordance with the provisions of this Agreement.

Article 24
Compliance with National Laws

Except where otherwise provided in Agreements between the Contracting Parties, including this Agreement:

(a) means of transport of one Contracting Party including persons and goods shall, when in the

CERTIFIED COPY DEPUTY SECRETARY-GENERAL, THE ASEAN SECRETARIAT

territory of the other Contracting Party, comply with national laws and regulations in force in that territory;

(b) neither of the Parties shall impose on persons or goods of the other Contracting Party requirements which are more restrictive than those applied by its national laws and regulations on its own means of transport; and

(c) the host Contracting Party may temporarily or permanently deny access to its territory to a person, driver, transport operator, means of transport that has infringed national laws and regulations or this Agreement.

Article 25
Transparency

1. The Contracting Parties shall ensure transparency of their respective laws, regulations and administrative procedures which affect the facilitation of inter-state transport of goods under this Agreement and its Protocols.

2. For this purpose, all Contracting Parties shall deposit with the ASEAN Secretariat, not later than six months after this Agreement has entered into force, their aforementioned laws, regulations and administrative procedures.

3. If the aforementioned documents are not in the English language, their English translation shall also be deposited within one year after this Agreement has entered into force.

Article 26
Assistance for Traffic Accidents

Should the means of transport of one Contracting Party including persons and goods be involved in traffic accidents in the territory of another Contracting Party, the latter shall

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

provide all possible assistance to the means of transport, including persons and goods, and notify the appropriate authorities of the Contracting Party concerned as soon as possible.

PART VI
INSTITUTIONAL ARRANGEMENTS

Article 27
Institutional Arrangements

1. The National Transit Transport Coordinating Committee, established under Article 29 of the ASEAN Framework Agreement on the Facilitation of Goods in Transit signed in Ha Noi on 16 December 1998, of each Contracting Party shall also be responsible for the coordination and implementation of this Agreement.

2. The Transit Transport Coordinating Board, established under Article 29 of the ASEAN Framework Agreement on the Facilitation of Goods in Transit signed in Ha Noi on 16 December 1998, shall also oversee the overall coordination and implementation of this Agreement. The Board is further authorized to invite and seek the assistance of other relevant ASEAN coordinating bodies, for all matters related to the implementation of this Agreement.

3. The Transit Transport Coordinating Board shall make periodic reports on the implementation of this Agreement, and seek appropriate guidance on significant issues as necessary, from the relevant ASEAN Ministerial bodies.

4. The ASEAN Secretariat shall assist the Transit Transport Coordinating Board in its functions and responsibilities under this Agreement, and in particular, in the monitoring and reporting of the progress of the implementation of this Agreement. The ASEAN Secretariat shall submit evaluation reports to the Transit Transport Coordinating Board, for further action.

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

PART VII
FINAL CLAUSES

Article 28
Dispute Settlement

The provisions of the ASEAN Protocol on Enhanced Dispute Settlement Mechanism, done at Vientiane, Lao PDR on the 29th day of November 2004 and any amendment thereto, shall apply to disputes arising under this Agreement.

Article 29
Other Agreements in Force

This Agreement or any actions taken thereto shall not affect the rights and obligations of the Contracting Parties under any existing agreements or International Conventions to which they are also Contracting Parties.

Article 30
Implementation Arrangements

៤១- លោកព្រិន្ទបាលទោ	នៃ	ក៉ារី	អត្តលេខ ៤៧៨៥៣
៤២- លោកព្រិន្ទបាលទោ	ហ៊ី	វ៉ាន់ឈាង	អត្តលេខ ៤៨១៨០
៤៣- លោកព្រិន្ទបាលទោ	ជ្រិន	ហម	អត្តលេខ ៤៦៤៧២
៤៤- លោកព្រិន្ទបាលទោ	អ៊ីវ	សុខឃីម	អត្តលេខ ២៥១៩៣
៤៥- លោកព្រិន្ទបាលទោ	ឈួន	តេង	អត្តលេខ ៤៦៥៧៩
៤៦- លោកពលបាលឯក	សុខ	សុខុន	អត្តលេខ ៦១៤៩៦
៤៧- លោកពលបាលឯក	ជិក	សុខេម	អត្តលេខ ៦១៦០៨
៤៨- លោកពលបាលឯក	ផាំ	ពី	អត្តលេខ ៥១៤០៤
៤៩- លោកពលបាលឯក	ឡុប	ម៉េងហួរ	អត្តលេខ ៥៩៣១៦
៥០- លោកពលបាលឯក	មែ	សុជា	អត្តលេខ ៥៩៣១៨

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកម.១៣០៥.៥៧១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

លេខៈ ៥៧៧ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្ទេរបញ្ចូលមន្ត្រីរាជការ ០១រូប ទៅក្នុងឋានន្តរសក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ:

ល.រ	គោត្តនាម និង នាម	ភេទ	ឋានន្តរសក្តិ ថ្នាក់ចាស់	ឋានន្តរសក្តិ ថ្នាក់ថ្មី
១	**សួរ សុន**	ប្រុស	នាយក្រមការ ថ្នាក់លេខ ២	អនុមន្ត្រី ថ្នាក់លេខ ៧

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៨១.១៣០៥.៥៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣

លេខ: ៥៩៣ ស.ណ

សំណៅចំលងចេញតាមច្បាប់ដើម សំរាប់ការចែកផ្សាយ

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

គុណ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឈិត ម៉ូរ៉ាឌុន** ជាមេធាវីរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស. ១៧០៥. ៥៦៣

លេខៈ ៥៣៩ ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៨៤២,៧៤១១ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៣៤៨គ្រួសារ បម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងរក្សាទុក មួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២១៧លស ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ ៨៤២,៧៩១១ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៤១៦,៧០៥៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង ដីទំហំ ៣៥៦,៣៨៨២ ហិកតា បម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងដីទំហំ ៦៩,៦៤៧៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិដំណាក់ឈើក្រំ ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣៩៨គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិដំណាក់ឈើក្រំ ឃុំស្នាយអញ្ជិត ស្រុកជុំគីរី ខេត្តកំពត ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ១.០៦២,៨២៤៧ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីផែនទីគម្រប ព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៤៨១គ្រួសារ និងរក្សាទុកមួយចំណែកជាដី សាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ១៩០ល.ស ចុះថ្ងៃទី២៦ខែ មេសា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រង ដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ដីសរុបទំហំ ១០៦២,៨២៤៧ ហិកតា ចេញពីដែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ៩៩៣,៩៤៨៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៦៨,៨៧៦២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅ**ភូមិមនោសុខ ឃុំតាកែន ស្រុកឈូក ខេត្តកំពត** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៩៨១គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅ**ភូមិមនោសុខ ឃុំតាកែន ស្រុកឈូក ខេត្តកំពត** ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៩៩,៧៣៣៥ ហិកតា នៅស្រុកជុំគីរី ខេត្តកំពត ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១០៣គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ១៨៥ល.ស ចុះថ្ងៃទី២៦ខែ មេសា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ ៩៩,៧៣៣៥ ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ៩៤,៧២៣៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៥,០០៩៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិធ្លកយុល ឃុំស្រែសំរោង ស្រុកជុំគីរី ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១០៣គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិធ្លកយុល ឃុំស្រែសំរោង ស្រុកជុំគីរី ខេត្តកំពត ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្ដែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៣៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ២.៧២៣,២២ ហិកតា នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងនោះ កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីសម្បទានរបស់ក្រុមហ៊ុន ម៉ុង រិទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.២៦៨ គ្រួសារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៨៩ សណ/១៣ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ **២.៧២៣,២២ ហិកតា** ក្នុងនោះ (១) ទំហំ **៣៩១,៧០ ហិកតា** កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និង (២) ទំហំ **២.៣៣១,៥២ ហិកតា** កាត់ចេញពីដីសម្បទានរបស់ក្រុមហ៊ុន ម៉ុង រិទ្ធី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលស្ថិតក្នុងភូមិ ដូចខាងក្រោម ៖

- កាត់ផ្ទៃដីសរុបទំហំ **២.០៩០,៦៣ ហិកតា** ក្នុងនោះ (១) ទំហំ **២,៨៦ ហិកតា** កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និង (២) ទំហំ **២.០៨៧,៧៧ ហិកតា** កាត់ចេញពីដីសម្បទានរបស់ក្រុមហ៊ុន ម៉ុង រិទ្ធី សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិតានៃ
- កាត់ផ្ទៃដីសរុបទំហំ **៦៣២,៥៩ ហិកតា** ក្នុងនោះ (១) ទំហំ **៣៨៨,៨៤ ហិកតា** កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និង (២) ទំហំ **២៤៣,៧៥ ហិកតា** កាត់ចេញពីដីសម្បទានរបស់ក្រុមហ៊ុន ម៉ុង រិទ្ធី សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិមនោរម្យ

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១, ២, ៣ , ៤, ៥, ៦, ៧ និងឧបសម្ព័ន្ធទី៨ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជន ជូនប្រជាពលរដ្ឋសរុបចំនួន ១.២៦៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសហនុ ស្ថិតនៅក្នុងភូមិ ដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៤២ គ្រួសារ នៅភូមិតានៃ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥២៦ គ្រួសារ នៅភូមិមនោរម្យ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តព្រះសីហនុ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើ ផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៥ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការកាត់ដីទំហំ ៣.៩៨០,៤០ ហិកតា នៅស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.២៩៧ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ០៨៣សណ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៣.៩៨០,៤០ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៣.២៩៧,៣១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៦៨៣,០៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ស្ថិតនៅក្នុងភូមិ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ២.៥៩៦,២៦ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្មដីទំហំ ២.៣២៤,៤៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ២៧១,៧៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃក្ដួច
- ផ្ទៃដីទំហំ ១.៣៨៤,១៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្មដីទំហំ ៩៧២,៨២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៤១១,៣២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងស្គារ

តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូន

ប្រជាពលរដ្ឋចំនួន ១.៤៩៧ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ នៅក្នុងភូមិ ដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨២០គ្រួសារ នៅភូមិព្រៃក្លូច
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៧៧គ្រួសារ នៅភូមិត្រពាំងស្គារ ។

មាត្រា ៣..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៩ សរណន

សារាចរណែនាំ
ស្តីពី
ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

១- ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ទោះបីជាកម្ពុជាបានជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដូចជាបច្ច័យពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិនិងការធ្លាក់ចុះសេដ្ឋកិច្ចសកល សង្គ្រាមនៅព្រំដែនបង្ក ឡើងដោយការឈ្លានពានពីកងទ័ពថៃ គ្រោះទឹកជំនន់ រាជរដ្ឋាភិបាលកម្ពុជាបានគ្រប់គ្រងប្រទេស ដោយជំនះបានលើឧបសគ្គទាំងនោះប្រកបដោយជោគជ័យ គឺការពារបានទាំងស្រុងនូវអធិបតេយ្យ និង បូរណភាពទឹកដី រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ និងរក្សាបាននូវលំនឹងនិង ប្រក្រតីភាពនៃជីវភាពរស់នៅរបស់ប្រជាជន។ លើសពីនេះទៀត កម្ពុជាត្រូវបានចាត់ទុកជាប្រទេស មានសេដ្ឋកិច្ចលូតលាស់លឿននៅអាស៊ី ហើយក៏ជាប្រទេសមួយក្នុងចំណោម ៥ប្រទេស ដែលកំពុងធ្វើ ដំណើរឆ្ពោះទៅសម្រេចបានតាមគោលដៅសហស្សវត្សរ៍ក្នុងឆ្នាំ២០១៥ ខាងមុខ។

២- ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុ សាធារណៈប្រកបដោយភាពប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្របដែល បានធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាអាចទប់ទល់បាននឹងវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះសេដ្ឋកិច្ច សកល ហើយឈានទៅរក្សាកំណើនប្រកបដោយស្ថិរភាព។ ជាក់ស្តែង ក្នុងឆ្នាំ២០០៩ ជាឆ្នាំដែលកម្ពុជា បានទទួលផលប៉ះពាល់ពីវិបត្តិនេះក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជាសម្រេចបាននូវកំណើនវិជ្ជមានគឺ០,១% ក្នុងឆ្នាំ២០១០ មានកំណើន៦% ក្នុងឆ្នាំ២០១១ មានកំណើន៧,១% ក្នុងឆ្នាំ២០១២ មានកំណើន ៧,៣% ហើយត្រូវបានព្យាករណ៍ថានឹងមានកំណើនប្រមាណ៧% ក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៤។ ការព្យាករកំណើនសេដ្ឋកិច្ច៧% ក្នុងឆ្នាំ២០១៤ គឺបានមកពីវិស័យកសិកម្មនឹងបន្តរក្សាកំណើនក្នុង រង្វង់៣,៨% វិស័យឧស្សាហកម្មអាចនឹងមានកំណើន១០% និងវិស័យសេវាកម្មអាចនឹងមានកំណើន ប្រមាណ៦,៨%។

៣- ការសម្រេចបាននូវស្ថិរភាពកំណើនសេដ្ឋកិច្ចនេះពិតជាបានរួមចំណែកធ្វើឲ្យការអនុវត្តថវិកា សម្រេចបានលទ្ធផលល្អប្រសើរប្រាកដមែន ជាក់ស្តែងចំណូលក្នុងស្រុកថវិកាជាតិឆ្នាំ២០១១ សម្រេច

បានកំណើន៨,៣% ស្មើនឹង១២,៨៥% នៃផ.ស.ស. និងឆ្នាំ២០១២ សម្រេចបានកំណើន២២,៨% ស្មើនឹង១៤,៥១% នៃផ.ស.ស.។ តាមការព្យាករចំណូលក្នុងស្រុកថវិកាជាតិឆ្នាំ២០១៣នេះ នឹងសម្រេចបានកំណើន១១,៥% ស្មើនឹង១៤,៦៩% នៃផ.ស.ស.។ ដូច្នេះ បើគិតពីឆ្នាំ២០១១-២០១៣ ចំណូលក្នុងស្រុកថវិកាជាតិបានកើនឡើងក្នុងមធ្យមភាគប្រមាណ១៤% ក្នុងមួយឆ្នាំ ធៀបនឹងការអនុវត្តចំណូលប្រចាំឆ្នាំ និងបានកើនឡើងក្នុងមធ្យមភាគប្រមាណ០,៦% នៃផ.ស.ស. ក្នុងមួយឆ្នាំ។

៤- ទន្ទឹមនឹងការអនុវត្តនយោបាយហិរញ្ញវត្ថុសាធារណៈតាមរយៈការធ្វើវិត្តកម្មចំណាយដើម្បីរួមចំណែកក្នុងការជំរុញស្ថិរភាពកំណើនសេដ្ឋកិច្ច ទប់ទល់នឹងបញ្ហាព្រំដែន អតិផរណាខ្ពស់ និងទឹកជំនន់ ចំណាយសរុបថវិកាជាតិក្នុងឆ្នាំ២០១១ បានកើនឡើងខ្ពស់ហួតដល់២១,០២% នៃផ.ស.ស. ហើយបានធ្លាក់ចុះមកវិញនៅត្រឹម២០,៥៥% នៃផ.ស.ស. ក្នុងឆ្នាំ២០១២ និងតាមការព្យាករចំណាយសរុបថវិកាជាតិក្នុងឆ្នាំ២០១៣ នឹងស្ថិតនៅត្រឹម២០,២៤% នៃផ.ស.ស.។ ឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយពី-៨,១៦% នៃផ.ស.ស. ក្នុងឆ្នាំ២០១១ មកនៅត្រឹម-៦,០៣% ក្នុងឆ្នាំ២០១២ និងតាមការព្យាករឱនភាពថវិកាសរុបនឹងស្ថិតនៅត្រឹម-៥,៥៥% នៃផ.ស.ស. ក្នុងឆ្នាំ២០១៣។ សម្រាប់ឆ្នាំ២០១៤ រាជរដ្ឋាភិបាលមានគោលដៅនឹងរក្សាឱនភាពថវិកាសរុបឲ្យស្ថិតនៅក្នុងរង្វង់-៥% នៃផ.ស.ស. ហើយដើម្បីសម្រេចបានតាមគោលដៅនេះ ចំណូលក្នុងស្រុកថវិកាជាតិឆ្នាំ២០១៤ ត្រូវសម្រេចឲ្យបាន១៥,២៣% នៃផ.ស.ស. និងចំណាយសរុបថវិកាជាតិឆ្នាំ២០១៤ ត្រូវរក្សាឲ្យនៅត្រឹម២០,១៣% នៃផ.ស.ស.។

៥- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ គឺស្ថិតក្នុងបរិការណ៍ដែលសេដ្ឋកិច្ចតំបន់ និងពិភពលោកស្ថិតក្នុងស្ថានភាពមានកំណើនខ្ពស់ជាងមុនតែហានិភ័យនៅតែបន្តមាន ដូចជាបញ្ហាឱនភាពសេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចជប៉ុន និងកំណើនសេដ្ឋកិច្ចយឺតរបស់សហរដ្ឋអាមេរិក គួបផ្សំនឹងបរិការណ៍នយោបាយអន្តរជាតិធំៗ ដូចជាស្ថានភាពតានតឹងនៅឧបទ្វីបកូរ៉េ ភាពតានតឹងនៅសមុទ្រចិន និងភាពតានតឹងនៃកម្មវិធីនុយក្លេអ៊ែរប្រទេសអ៊ីរ៉ង់ ដែលកត្តាទាំងនេះនឹងបង្កជាបច្ច័យអវិជ្ជមានដែលមិនអាចទស្សន៍ទាយបានដល់សេដ្ឋកិច្ចសកល និងសេដ្ឋកិច្ចកម្ពុជា។ ទន្ទឹមនឹងនេះ បញ្ហាអតិផរណាដោយសារការឡើងថ្លៃប្រេង ការឡើងថ្លៃទំនិញនាំចូល និងការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្ម ក៏នៅតែជាបញ្ហាប្រឈមសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ផងដែរ។

II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៤

ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៦- តាមការគណនារបស់វិទ្យាស្ថានជាតិស្ថិតិបង្ហាញថា កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១២ អាចសម្រេចបាន៧,៣% ក្នុងនោះ វិស័យកសិកម្មអាចសម្រេចបានកំណើន៤,៣% វិស័យឧស្សាហកម្មអាចសម្រេចបានកំណើន៩,២% និងវិស័យសេវាកម្មអាចសម្រេចបានកំណើន៨,១%។ តាមការព្យាករដោយប្រយ័ត្នប្រយែង និងដោយផ្អែកលើនិន្នាការសេដ្ឋកិច្ចដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៣នេះ អាចនឹងបន្តសម្រេចបាន៧% ដូចដែលបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង

ឆ្នាំ២០១៣។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៤,៤% ដោយសារការបន្តកើនឡើងនៃដំណាំស្រូវ ដំឡូងមី កៅស៊ូ និងអំពៅ។ វិស័យឧស្សាហកម្មនឹងមានកំណើន១០% ដោយសារការបន្តកើនឡើងនៃផ្នែកវាយនភណ្ឌ ការរីកចម្រើនវិស័យឧស្សាហកម្មធុនស្រាល និងផលិតផលនៃច្រវាក់ផ្គត់ផ្គង់សាកល។ វិស័យសេវាកម្មនឹងមានកំណើន៦,៥% ដែលកំណើននេះបានមកពីកំណើនវិស័យដឹកជញ្ជូននិងទូរគមនាគមន៍ វិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុ និងវិស័យសេវាបម្រើម្ចាស់អចលនទ្រព្យ។

៧- កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤ តាមការព្យាករណ៍អាចនឹងបន្តសម្រេចបានក្នុងរង្វង់ ៧%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ ៣,៨% ដោយសារការកើនឡើងនៃកសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុកនិងតម្រូវការទីផ្សារអន្តរជាតិ មានដូចជា ស្រូវ ពោត ដំឡូងមី កៅស៊ូ និងអំពៅ ជាដើម។ វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ១០% ដោយរំពឹងថាវិស័យវាយនភណ្ឌនឹងអាចកើនឡើងប្រមាណ៩,៩% ដោយសារការនាំចេញទៅសហគមន៍អឺរ៉ុបនៅបន្តមិនយកពន្ធក្រោមកម្មវិធី "ទំនិញគ្រប់មុខ លើកលែងតែសព្វាវុធ" និងសក្តានុពលដែលអាចពង្រីកផលិតកម្មនិងទីផ្សារនៃវិស័យនេះ។ ម្យ៉ាងទៀត គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករក៏បានជំរុញឲ្យមានការកើនឡើងខ្ពស់ខាងវិស័យកែច្នៃម្ហូបអាហារ និងវិស័យដែលទាក់ទងមួយចំនួនទៀត ដែលបានបង្កើនតម្លៃបន្ថែមលើផលិតផលដែលមានស្រាប់។ លើសពីនេះ គម្រោងវិនិយោគមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី ទាំងអគ្គិសនីប្រើប្រាស់ធ្យូងថ្មនឹងត្រូវបានដាក់ឲ្យដំណើរការជាបន្តបន្ទាប់ និងឧស្សាហកម្មធុនស្រាលដទៃទៀតក៏បង្កើនសកម្មភាពកាន់តែខ្លាំងក្លាដែរ។ វិស័យសេវាកម្មអាចនឹងសម្រេចបានកំណើនប្រមាណ៦,៨% ដោយសារការកើនឡើងនៃវិស័យទេសចរណ៍ វិស័យដឹកជញ្ជូន វិស័យហិរញ្ញវត្ថុ និងវិស័យសេវាបម្រើម្ចាស់អចលនទ្រព្យ។ សកម្មភាពសេដ្ឋកិច្ចទូទៅដែលជួយជំរុញកំណើនសេដ្ឋកិច្ចនឹងបន្តកើនឡើងក្នុងល្បឿនលឿន ដោយសារការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងគោលនយោបាយស្ថិរភាពរូបិយវត្ថុ ដូចជាគោលនយោបាយជំរុញហិរញ្ញប្បទានក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងគោលនយោបាយសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យឧស្សាហកម្ម។ វិស័យអចលនទ្រព្យនិងសំណង់នឹងបន្តកើនឡើងដោយសារតម្រូវការមានការកើនឡើង តាមរយៈលំហូរទុនចូលពីវិនិយោគបរទេស និងកំណើនសេដ្ឋកិច្ចខ្ពស់។

៨- អតិផរណានៅឆ្នាំ២០១២ មាន២,៩% ការសម្រេចបានអតិផរណាកម្រិតទាបនេះដោយសារមានការគ្រប់គ្រងប្រុងប្រយ័ត្នបំផុតទៅលើគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុសាធារណៈក្នុងការបង្កើនសកម្មភាពសេដ្ឋកិច្ច-សង្គមកិច្ច ទោះបីជាអតិផរណានៅក្នុងតំបន់ និងពិភពលោកមានកម្រិតខ្ពស់ហើយប្រាក់ដុល្លារគ្មានស្ថិរភាពក៏ដោយ។ តាមការប៉ាន់ស្មាន អតិផរណានៅឆ្នាំ២០១៣ នឹងមានកម្រិត ៤% គឺដូចគ្នាទៅនឹងការព្យាករក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដោយសារតម្រូវការចំណាយនៅក្នុងឆ្នាំ២០១៣ នឹងមានកំណើនខ្ពស់ ទាំងផ្នែកសាធារណៈនិងផ្នែកឯកជន រួមទាំងការចំណាយសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភានីតិកាលទី៥ ជាដើម។

តាមការព្យាករ អតិផរណាប្រចាំឆ្នាំ២០១៤ នឹងមានកម្រិត៣,៥% ដោយសារមានស្ថិរភាពថ្លៃម្ហូបអាហារ និងស្ថិរភាពហិរញ្ញវត្ថុ។

៩- អត្រាប្តូរប្រាក់នៅឆ្នាំ២០១២ មានតម្លៃជាមធ្យម៤ ០៣៤រៀល ក្នុង១ដុល្លារអាមេរិក។ តាមការប៉ាន់ស្មាន អត្រាប្តូរប្រាក់នៅឆ្នាំ២០១៣ នឹងមានតម្លៃជាមធ្យម៤ ០០០រៀល ក្នុង១ដុល្លារអាមេរិក គឺដូចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ប៉ុន្តែទាបជាងធៀបនឹងការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលមានតម្លៃ៤ ០៥០រៀលក្នុង១ដុល្លារអាមេរិក។ ការឡើងថ្លៃប្រាក់រៀលគឺដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងការជឿទុកចិត្តពីសាធារណជន និងជាពិសេស គោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈនិងគោលនយោបាយរូបិយវត្ថុសមស្រប។ តាមការព្យាករ នៅឆ្នាំ២០១៤ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ៤ ០០០រៀល ក្នុង១ដុល្លារអាមេរិក ដែលកម្មវត្ថុចម្បងគឺដើម្បីរក្សាតុល្យភាពនៃការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោក និងការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុកប្រាក់រៀល។

១០- ឱនភាពគណនីចរន្តបានកើនឡើងវិញគឺពី-៣,៧៨% នៃផ.ស.ស. នៅឆ្នាំ២០១១ មក -៦,៦៣% នៃផ.ស.ស. នៅឆ្នាំ២០១២ ដោយសារការកើនឡើងការនាំចូលវត្ថុធាតុដើម និងឧបករណ៍បរិក្ខារផលិតកម្មនៃវិនិយោគផ្ទាល់ពីបរទេស។ តាមការព្យាករ ឱនភាពគណនីចរន្តនឹងធ្លាក់ចុះបន្តិចមកវិញនៅត្រឹម-៦,៤២% នៃផ.ស.ស. នៅឆ្នាំ២០១៣ និង-៦,៣៥% នៃផ.ស.ស. នៅឆ្នាំ២០១៤។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឲ្យការនាំចូលជាបណ្តើរៗ។ ទុនបម្រុងអន្តរជាតិនៅឆ្នាំ២០១២ មានចំនួន៣ ២៦៥លានដុល្លារអាមេរិក ឬប្រមាណ៤,៩ខែ នៃការនាំចូលទំនិញនិងសេវាប្រើប្រាស់ក្នុងស្រុក។ ទុនបម្រុងអន្តរជាតិនៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ អាចកើនឡើងលើសពី៤ពាន់លានដុល្លារអាមេរិក ដែលអាចធានាបានប្រមាណជាង ៤,៥ខែ នៃការនាំចូលទំនិញនិងសេវាប្រើប្រាស់ក្នុងស្រុក។

១១- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ មានគោលបំណងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពតម្លៃ ការបង្កើនការងារធ្វើ និងចីរភាពបំណុល។ ដើម្បីសម្រេចបាននូវគោលដៅរយៈពេលមធ្យមនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលពោលគឺបន្តខិតខំដើម្បី (១)សម្រេចបាននូវអត្រាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៧% (២)រក្សាអត្រាអតិផរណាឲ្យស្ថិតនៅក្រោម៥% (៣)កំណត់បំណុលបរទេសឲ្យមានកម្រិតប្រហាក់ប្រហែលនឹងលំហូរនៃហិរញ្ញប្បទាននិងការវិនិយោគផ្ទាល់ពីបរទេស និង(៤)រក្សាទុនបម្រុងអន្តរជាតិឲ្យស្មើនឹងការនាំចូលចំនួនបីខែ។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅនៃកំណើន ផ.ស.ស.ពិតឲ្យសម្រេចបានក្នុងរង្វង់៧% នៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ និងខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឲ្យស្ថិតក្នុងរង្វង់៤% ក្នុងឆ្នាំ២០១៣ និង៣,៥% ក្នុងឆ្នាំ២០១៤។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងធានារក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលឲ្យស្ថិតនៅក្នុងរង្វង់៤ ០០០រៀលក្នុង១ដុល្លារអាមេរិក ដោយខិតខំជំរុញបដិដុល្លារូបិយកម្មសេដ្ឋកិច្ចនៅចំពោះមុខ និងរយៈពេលវែងតាមរយៈការលើក

កម្ពស់គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។ លើសពីនេះ សម្រាប់រយៈពេលមធ្យមខាងមុខ(២០១៤-២០១៦) រាជរដ្ឋាភិបាលមានគោលដៅរក្សាកំណើនប្រចាំឆ្នាំឲ្យបានក្នុងរង្វង់៧% អត្រាអតិផរណាក្នុងរង្វង់៤% និងអត្រាប្តូរប្រាក់រៀលក្នុងរង្វង់៤ ០០០រៀល ក្នុង១ដុល្លារអាមេរិក។

ខ- គ្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកា

១២- គោលនយោបាយហិរញ្ញវត្ថុសាធារណៈមានគោលដៅសំខាន់ៗដូចតទៅ ៖

- ជានាបន្តអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល ***ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន*** ដោយធានាបានទាំងស្រុងនូវការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យដែលផ្តល់អាទិភាពទៅលើ៖

- បន្តលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈការប្រយុទ្ធប្រឆាំងអំពើពុករលួយ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

- បន្តបង្កើនការលើកស្ទួយវិស័យកសិកម្មតាមរយៈការលើកកម្ពស់ផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម កំណែទម្រង់ដីធ្លីនិងការបោសសម្អាតមីន កំណែទម្រង់ជលផល និងកំណែទម្រង់ព្រៃឈើ។

- បន្តបង្កើនការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមរយៈការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ ការអភិវឌ្ឍវិស័យថាមពលនិងបណ្តាញអគ្គិសនី និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។

- បន្តអភិវឌ្ឍផ្នែកឯកជននិងការងារតាមរយៈការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករនិងនិយោជិក ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម។

- បន្តកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំ ការលើកកម្ពស់សេវាសុខាភិបាល ការអនុវត្តគោលនយោបាយយេនឌ័រ និងការអនុវត្តគោលនយោបាយប្រជាជន។

- ជានាបន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព។
- ជានាបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ២០១៤-២០១៦។
- ជានាបន្តអនុវត្តកម្មវិធីកែទម្រង់ កម្មវិធីអភិវឌ្ឍន៍គ្រប់ការដ្ឋាន និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។
- ជានាបន្តអនុវត្តគោលនយោយបាយចាស់សកម្មភាពថ្មីនៃវិស័យដីធ្លី ពិសេសការវាស់វែងនិងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ និងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ។

• ជានាបង្កើនចំណាយវិនិយោគក្នុងស្រុកដោយខិតខំសន្សំពីអតិរេកថវិកាចរន្ត ដើម្បីកាត់បន្ថយជាបណ្តើរៗនូវចំណាយវិនិយោគសាធារណៈដែលផ្តល់ហិរញ្ញប្បទានពីក្រៅប្រទេស ក្នុងគោលដៅរក្សាឱនភាពថវិកាសរុបឲ្យស្ថិតនៅក្នុងរង្វង់-៥% នៃផ.ស.ស.។

• ជានាបន្តការពារឲ្យបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ។

• ពង្រឹង និងបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ ដែលបានប្រើប្រាស់ក្នុងអំឡុងពេលមានវិបត្តិកន្លងមក។

• ជានាផ្តល់ការឆ្លើយតបដោយទាន់ពេលវេលា និងដោយប្រសិទ្ធភាពចំពោះវិបត្តិ និងឧបទ្ទវហេតុផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ដូចជាគ្រោះធម្មជាតិជាដើម។

១៣- ដើម្បីសម្រេចបានតាមគោលដៅខាងលើ គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៤-២០១៦ មានគោលដៅបង្កើនការប្រមូលចំណូលឲ្យមានកំណើនប្រមាណ០,៥% នៃផ.ស.ស. ក្នុងមួយឆ្នាំ ហើយពង្រឹងវិន័យ និងបង្កើនគុណភាពចំណាយដោយបន្តឥ្សិតត្បៀតចំណាយចរន្តតាមរយៈការធ្វើវិចារណកម្ម និងការធ្វើអាទិភាវូបនីយកម្មចំណាយជាមួយនឹងការបង្កើនចំណាយវិនិយោគក្នុងគោលដៅរក្សាអតិរេកថវិកាចរន្តឲ្យបានក្នុងរង្វង់៣% នៃផ.ស.ស. និងឱនភាពថវិកាសរុបឲ្យស្ថិតក្រោម-៥% នៃផ.ស.ស.ក្នុងមួយឆ្នាំ។ ដើម្បីសម្រេចគោលដៅនេះ ថវិកាឆ្នាំ២០១៣ និងឆ្នាំ២០១៤ត្រូវបានកំណត់ដូចខាងក្រោម៖

• ចំណូលក្នុងស្រុកថវិការដ្ឋនៅឆ្នាំ២០១៣ ត្រូវសម្រេចឲ្យបាន១៤,៦៩% នៃផ.ស.ស. (ថ្នាក់ជាតិ១៣,៩៩% និងថ្នាក់ក្រោមជាតិ០,៧០%) ក្នុងនោះចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឲ្យបាន១៤,៥៦% នៃផ.ស.ស. និងចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឲ្យបាន០,១៣% នៃផ.ស.ស.។ ចំណូលចរន្តថវិការដ្ឋដែលត្រូវសម្រេចឲ្យបាន១៤,៥៦% នៃផ.ស.ស. គឺចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវសម្រេចឲ្យបាន៦,៥២% នៃផ.ស.ស. ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៥៦% នៃផ.ស.ស. (ថ្នាក់ជាតិ៤,៩០% និងថ្នាក់ក្រោមជាតិ០,៦៦%) ចំណូលសារពើពន្ធផ្សេងៗទៀតត្រូវសម្រេចឲ្យបាន០,៣៦% នៃផ.ស.ស. និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន២,១៣% នៃផ.ស.ស.។ ចំណូលក្នុងស្រុកថវិការដ្ឋឆ្នាំ២០១៤ ត្រូវសម្រេចឲ្យបាន១៥,២៣% នៃផ.ស.ស. (ថ្នាក់ជាតិ១៤,២៤% និងថ្នាក់ក្រោមជាតិ០,៩៩%) ក្នុងនោះចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឲ្យបាន១៥,០៦% នៃផ.ស.ស. និងចំណូលមូលធនក្នុងប្រទេសត្រូវសម្រេចឲ្យបាន០,១៧% នៃផ.ស.ស.។ ចំណូលចរន្តថវិការដ្ឋដែលត្រូវសម្រេចឲ្យបាន១៥,០៦% នៃផ.ស.ស. គឺចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវសម្រេចឲ្យបាន៦,៧០% នៃផ.ស.ស. ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៩០% នៃផ.ស.ស. (ថ្នាក់ជាតិ៤,៩៦% និងថ្នាក់ក្រោមជាតិ០,៩៤%) ចំណូលសារពើពន្ធផ្សេងៗទៀតត្រូវសម្រេចឲ្យបាន០,៣១% នៃផ.ស.ស. និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន២,១៤% នៃផ.ស.ស.។

• ចំណាយសរុបថវិការដ្ឋត្រូវរក្សាឲ្យនៅត្រឹម២០,២៤% នៃផ.ស.ស.(ថ្នាក់ជាតិ១៩,៥៥% និងថ្នាក់ក្រោមជាតិ០,៩០%) នៅឆ្នាំ២០១៣ ដោយចំណាយចរន្តថវិការដ្ឋត្រូវរក្សាឲ្យបានត្រឹម

១២,២២% នៃផ.ស.ស.(ថ្នាក់ជាតិ១១,៧២% និងថ្នាក់ក្រោមជាតិ០,៧១%) និងចំណាយមូលធនត្រឹម៨,០២% នៃផ.ស.ស.។ ចំណាយសរុបថវិកាជាតិឆ្នាំ២០១៤ ត្រូវរក្សាឲ្យនៅត្រឹម២០,១៣% នៃផ.ស.ស. (ថ្នាក់ជាតិ១៩,៣៣% និងថ្នាក់ក្រោមជាតិ០,៩៩%) ដោយចំណាយចរន្តថវិកាជាតិនឹងកម្រិតត្រឹម១២,០៦% នៃផ.ស.ស.(ថ្នាក់ជាតិ១១,៤៧% និងថ្នាក់ក្រោមជាតិ០,៧៨%) ដោយក្នុងនោះរាជរដ្ឋាភិបាលកំពុងរៀបចំកែលម្អប្រព័ន្ធបៀវត្ស និងរៀបចំគោលនយោបាយដំឡើងប្រាក់បៀវត្សដោយផ្អែកលើកំណើនសេដ្ឋកិច្ច អតិផរណា និងលទ្ធភាពថវិកា ក្នុងទិសដៅលើកកម្ពស់ផលិតភាពការងារ បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងធានាបាននូវសមធម៌ ព្រមទាំងរក្សាបាននូវស្ថិរភាព និងចីរភាពហិរញ្ញវត្ថុសាធារណៈនិងម៉ាក្រូសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ ចំណាយមូលធននឹងរក្សាត្រឹម៨,០៧% នៃផ.ស.ស.។

១៤- ដើម្បីឲ្យក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើអាចសម្រេចបានតាមគោលដៅ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តបណ្តាគោលនយោបាយ និងកម្មវិធីកែទម្រង់សំខាន់ៗដូចខាងក្រោម៖

ក. បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដ៏ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាពក្នុងបរិការណ៍នៃអត្រាអតិផរណាសមស្រប។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តអប្បមាទជាប្រចាំ និងត្រៀមដាក់ចេញនូវបណ្តាវិធានការគោលនយោបាយថវិកាឬ/និងគោលនយោបាយរូបិយវត្ថុប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងទាន់ពេលវេលាដើម្បីទប់ទល់នឹង និងគ្រប់គ្រងលើសម្ពាធអតិផរណា និងការប្រែប្រួលនៃលំហូរមូលធន ដែលបាន និងកំពុងរាលដាល និងមានការយកចិត្តទុកដាក់ខ្ពស់នៅក្នុងតំបន់ក៏ដូចជានៅលើសកលលោក។

ខ. បន្តជំរុញការអភិវឌ្ឍតាមវិស័យ ពិសេស វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ បន្តជំរុញ និងបង្កើនការលើកស្ទួយវិស័យកសិកម្ម កសិឧស្សាហកម្ម និងជួយគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ពិសេស ជំរុញការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ព្រមទាំងជំរុញ និងលើកទឹកចិត្តដល់ផលិតកម្មនៃបណ្តាកសិផលមួយចំនួនទៀតដែលកំពុងមានសក្តានុពលខ្ពស់ដូចជា ដំឡូងមី ពោត និងកៅស៊ូ។ បន្តយកចិត្តទុកដាក់ខ្ពស់លើការបង្កើនគុណភាពសេវា វិស័យអប់រំ សុខាភិបាល និងការកសាងធនធានមនុស្ស ព្រមទាំងការងារបង្កើនសុវត្ថិភាពសង្គម។ បន្តជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ប្រព័ន្ធស្រោចស្រព ព្រមទាំងបន្តបង្កបរិយាកាស និងផ្តល់ការលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជន ពិសេស ការវិនិយោគក្នុងវិស័យកសិកម្ម និងតាមរយៈយន្តការជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

គ. បន្តជំរុញការអនុវត្តកំណែទម្រង់ការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបោសសម្អាតមីន ដោយផ្តោតជាសំខាន់លើការពង្រឹងប្រព័ន្ធគ្រប់គ្រង ការបែងចែកដីធ្លីប្រកបដោយសមធម៌ ការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ក្នុងនោះរួមទាំងដីសម្បទានសេដ្ឋកិច្ច ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លីឲ្យសមស្របតាមច្បាប់ភូមិបាល ដើម្បីជួយគាំទ្រដល់វិស័យកសិកម្ម សំដៅលើកកម្ពស់ផលិតភាព និងពិពិធកាវូបនីយកម្មកសិកម្ម ដើម្បីឲ្យវិស័យ

នេះក្លាយទៅជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ច ហើយជាបណ្តើរៗឈានទៅកសាងវិស័យឧស្សាហកម្ម ដោយផ្តើមចេញពីឧស្សាហកម្មកែច្នៃកសិផល និងក្នុងគោលដៅធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងបម្រើឲ្យគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ឃ. បន្តពង្រឹង និងពង្រីកប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង ទីផ្សារមូលបត្រ និងទីផ្សារភាគហ៊ុន ក្នុងក្របខ័ណ្ឌនៃការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីបង្កើនការកៀរគរធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងបង្កើនសក្តានុពលភាព និងកាលានុវត្តភាពដល់ការធ្វើហិរញ្ញប្បទាន និងការអភិវឌ្ឍវិស័យឯកជន។

ង. បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ជាពិសេស បន្តជំរុញការអនុវត្តផែនការសកម្មភាពជំហានទី២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដោយផ្តោតលើការរៀបចំ និងដាក់ឲ្យអនុវត្តនូវចំណាត់ថ្នាក់ថវិកាថ្មីបន្ថែមទៀត អង្គភាពថវិកា ស្តង់ដារគណនេយ្យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការសាកល្បងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា។ ទន្ទឹមនឹងនេះ ការបន្តពង្រឹងភាពជឿទុកចិត្តលើថវិកានៃជំហានទី១ តាមរយៈការបន្តជំរុញការកែលម្អនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាឲ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា។ ការបន្តកសាង និងកែលម្អក្របខ័ណ្ឌគោលនយោបាយចំណូលរយៈពេលមធ្យមដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពចំណូល ពិសេស ផ្តោតការយកចិត្តទុកដាក់លើការកសាង និងពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ យន្តការគ្រប់គ្រង និងការប្រមូលពន្ធ និងអាករ ព្រមទាំងចំណូលមិនមែនសារពើពន្ធ រួមទាំងចំណូលពីធនធានធម្មជាតិផង។ លើសពីនេះ ត្រូវបន្តជំរុញពង្រឹង និងបង្កើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ដែលជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាបណ្តើរៗ និងដើម្បីឈានទៅបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការបង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម ដែលជាគោលដៅនៃជំហានទី៣ និងទី៤។

ច. បន្តការជំរុញការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពិសេស ការពង្រឹង និងពង្រីករចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តគោលនយោបាយ ព្រមទាំងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះ បន្តកសាង និងកែលម្អច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសហការរៀបចំពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវ និងមុខងាររបស់ខ្លួន ដើម្បីកំណត់មុខងារ និងធនធានសម្រាប់ផ្ទេរឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងស្មារតីទទួលខុសត្រូវពីថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព។

ឆ. បន្តជំរុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការកែលម្អការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ។ ក្នុងន័យនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវរៀបចំគោលនយោបាយរយៈពេលមធ្យម និងវែងសម្រាប់ការកែលម្អការគ្រប់គ្រងធនធានមនុស្សប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ជាពិសេសត្រូវបង្កើតយន្តការ និងបង្កើន

ប្រសិទ្ធភាពនៃការត្រួតពិនិត្យក្របខ័ណ្ឌមន្ត្រីរាជការ ការពង្រឹងការផ្តល់ទិដ្ឋាការឲ្យជ្រើសមន្ត្រីថ្មីបន្ថែម ដោយផ្អែកលើការវិភាគលើតម្រូវការជាក់ស្តែង និងលទ្ធភាពថវិកាជាតិ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការចូលនិវត្តន៍។ ទន្ទឹមនឹងនេះ ត្រូវពិនិត្យពិចារណាឡើងវិញលើរាល់គោលនយោបាយ និងគោលការណ៍ដំឡើង និងផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ រួមទាំងការដំឡើងបៀវត្សមូលដ្ឋានប្រចាំឆ្នាំ ការដំឡើងកាំប្រាក់ ការអនុវត្តប្រាក់បំណាច់មុខងារ ការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចជា ប្រាក់ម៉ោង ប្រាក់យាម ប្រាក់បេសកកម្ម និងចំណាយប្រតិបត្តិការអាទិភាពជាដើម ដើម្បីធានាសមធម៌ តម្លាភាព សង្គតិភាព និងប្រសិទ្ធភាព។

ជ. បន្តជំរុញការអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេស ការពង្រឹងសមត្ថភាពដឹកនាំ វិជ្ជាជីវៈជំនាញ សហប្រតិបត្តិការ និងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងការកែសម្រួលរចនាសម្ព័ន្ធកងឯកភាពប្រយុទ្ធ និងការកាត់សោយកងទ័ព ដើម្បីធានាការប្រើប្រាស់ និងគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់។

ឈ. បន្តជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ពិសេស ការបន្តរៀបចំ និងពង្រឹងសមត្ថភាព អង្គភាពប្រឆាំងអំពើពុករលួយដើម្បីអាចដំណើរការ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក្នុងការអប់រំ ទប់ស្កាត់ និងបោសសម្អាតអំពើពុករលួយ។

III. ការគណនា និងវិភាជន៍ថវិកាឆ្នាំ២០១៤

ក- <u>គម្រោងចំណាយថវិកា</u>

១៥- ដើម្បីធានាបាននូវការអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈដែលបានកំណត់ខាងលើ ពិសេស ដើម្បីអនុវត្តតាមគោលការណ៍ និងវិធានការដូចបានគូសបញ្ជាក់ខាងលើ ការគ្រោងចំណាយថវិកាឆ្នាំ២០១៤ ត្រូវផ្អែកលើមូលដ្ឋាន ***បង្កើនប្រសិទ្ធភាពចំណាយ*** ដូចខាងក្រោម ៖

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយ អគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ជៀសវាងបេសកកម្មបរទេស ឬការរៀបចំប្រជុំនៅក្នុងប្រទេស ដែលពុំសូវចាំបាច់ បន្ថយការទិញសម្ភារៈប្រណិត ការទិញសម្ភារៈថ្មី និងការបោះពុម្ពដែលមិនសូវចាំបាច់ ព្រមទាំងផ្អាកការសាងសង់អគារថ្មី ឬការជួសជុលដែលមិនចាំបាច់ ដើម្បីរក្សាចំណាយសរុបថវិការដ្ឋឲ្យស្ថិតនៅត្រឹមកម្រិត២០,១៣% នៃផ.ស.ស. គឺកើនឡើង០,០៤% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលក្នុងនោះចំណាយចរន្តថវិការដ្ឋនឹងត្រូវរក្សាឲ្យនៅត្រឹម១២,០៦% នៃផ.ស.ស. (ថយចុះ០,០១% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣) និងចំណាយមូលធននឹងត្រូវរក្សាឲ្យនៅត្រឹម៨,០៧% នៃផ.ស.ស. (កើនឡើង០,០៥% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣) ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់២,៩៩% នៃផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់-៤,៩០% នៃផ.ស.ស.។ ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងកម្រិត២,៥៤% នៃផ.ស.ស. គឺកើនឡើង០,០២% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងចំណាយសម្រាប់វិស័យ

បំណុលត្រូវកំណត់ត្រឹម០,៤៨% នៃផ.ស.ស. គឺកើន០,០៣% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវបានគ្រោងក្នុងកម្រិត៥,០៤% នៃផ.ស.ស. គឺកើនប្រមាណ១០% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

• ត្រូវវិភាជន៍ចំណាយចរន្តថវិកាថ្នាក់ជាតិទៅតាមវិស័យនីមួយៗ ដូចតទៅៈ វិស័យសង្គមកិច្ចស្មើនឹង៤,៤៧% នៃផ.ស.ស. គឺកើនឡើង០,០៦% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ វិស័យសេដ្ឋកិច្ច១,០៤% នៃផ.ស.ស. គឺកើនឡើង០,០៩% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ វិស័យរដ្ឋបាលទូទៅ១,៦០% នៃផ.ស.ស. គឺថយចុះ០,១៦% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ វិស័យការពារជាតិនិងសន្តិសុខ២,៦០% នៃផ.ស.ស. គឺកើនឡើង០,០៣% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

• ថវិការាជធានី ខេត្ត ត្រូវកំណត់ត្រឹម០,៩៩% នៃផ.ស.ស. ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ០,៧៩% នៃផ.ស.ស. មានកំណើន០,០៩% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី ខេត្ត និងក្រុង ស្រុកស្មើនឹង០,២០% នៃផ.ស.ស. ដែលក្នុងនោះ ថវិកាដែលត្រូវផ្ទេរសម្រាប់មូលនិធិក្រុង ស្រុក សម្រាប់ឆ្នាំ២០១៤ ត្រូវបានកំណត់ស្មើនឹង០,៨% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំដោយឡែកសម្រាប់ការរៀបចំថវិកាថ្នាក់ក្រោមជាតិ ដោយឈរលើមូលដ្ឋាននៃសារាចរណែនាំនេះ ជាពិសេស ការកំណត់កញ្ចប់ និងការវិភាជន៍ថវិកាទៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគោរពទៅតាមគោលការណ៍ និងវិធានតាមជំពូកដូចបានកំណត់នៅក្នុងសារាចរណែនាំនេះ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល និងប្រសិទ្ធភាពចំណាយ ដើម្បីកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

១៦- ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០១៤ ត្រូវបន្តបម្រើឲ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ព្រមទាំងការលើកស្ទួយជីវភាពប្រជាជននៅទីជនបទ សំដៅសម្រេចឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ថវិកាឆ្នាំ២០១៤ ត្រូវផ្តល់ការវិភាជន៍ជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗ ដូចខាងក្រោមៈ

• បន្តរក្សាអាទិភាព និងវិចារណកម្មនៃគោលនយោបាយចំណាយដល់វិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាពសង្គម កសិកម្ម ដីធ្លី និងអភិវឌ្ឍន៍ជនបទ ព្រមទាំងការពង្រីកការកែលម្អ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន មន្ទីរពេទ្យ ។ល។

• បន្តផ្តល់មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ២០១៤ ក្នុងកម្រិត២,៨០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៣ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ហើយត្រូវបានគណនាស្មើនឹង០,៣៥% នៃផ.ស.ស.។

• ចំពោះថវិកាថ្នាក់ក្រោមជាតិ ត្រូវបន្តអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងរាល់នីតិវិធីដែលមានជាធរមានស្របតាមមាត្រា៨៧ នៃអនុក្រឹត្យនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ទាំងថវិកាផ្ទាល់ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិ ក្នុងពេលដែលការរៀបចំក្របខ័ណ្ឌគតិយុត្តិសម្រាប់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលកំណត់ និងផ្ទេរមុខងារដើម្បីឈានទៅបង្កើតថវិការាជធានី ខេត្ត និងក្រុង ស្រុក នៅពុំទាន់ចប់សព្វគ្រប់នៅឡើយ។

• បន្តផ្តល់អាទិភាពវិភាជន៍ថវិកាដល់ថវិកាកម្មវិធី និងផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានបញ្ជាក់ពីទិសដៅគោលនយោបាយ គោលបំណង កម្មវិធី និង/ឬយុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និងសូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងបង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ក្នុងគោលដៅបន្តពង្រឹង និងការកែលម្អការរៀបចំ និងការអនុវត្តថវិកាកម្មវិធី។

ខ- <u>គម្រោងចំណូលថវិកា</u>

១៧- ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃគម្រោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយចំណូល និងការអនុវត្តឲ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចឲ្យបាននូវកម្រិតចំណូលក្នុងស្រុកថវិការដ្ឋប្រមាណ១៥,២៣% នៃផ.ស.ស. គឺកើនឡើង០,៥៤% នៃផ.ស.ស. និងមានកំណើនប្រមាណ១៤,២% ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសម្រេចឲ្យបាន១២,៩៦% នៃផ.ស.ស. គឺមានកំណើន០,៥៣% នៃផ.ស.ស. ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣ និងចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឲ្យបាន២,១០% នៃផ.ស.ស. គឺថយចុះ០,០៣% នៃផ.ស.ស. ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ ចំណូលមូលធនក្នុងស្រុកត្រូវសម្រេចឲ្យបាន០,១៧% នៃផ.ស.ស. គឺកើនឡើង០,០៤% នៃផ.ស.ស. ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣។

១៨- ដើម្បីសម្រេចបានតាមគោលដៅនៃការប្រមូលចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តជំរុញឲ្យកាន់តែសកម្មថែមទៀតក្នុងការអនុវត្តសកម្មភាពការងារ និងបណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតលើបណ្តាវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

ទី១-<u>ផ្នែកចំណូលពន្ធដារ</u>

- បន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តឲ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈ៖

• បន្តពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ។
• ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ។

• ពង្រឹងការគ្រប់គ្រងប្រមូលពន្ធនៅតាមសាខាពន្ធដារខេត្ត ខណ្ឌ ដែលមានទាំងរបបឆ្លើយប្រកាស និងរបបម៉ៅការ ជាពិសេស ពង្រឹងការកំណត់ផលរបររបស់អ្នកជាប់ពន្ធឲ្យស្របតាមនឹងការជាក់ស្តែង ក្នុងទិសដៅបង្កើនអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស បន្ថយបរិមាណអ្នកជាប់ពន្ធតាមរបបម៉ៅការ និងពិនិត្យសហគ្រាសមួយចំនួនដែលមិនទាន់មកបង់ពន្ធឲ្យមកបង់ពន្ធ។

• បន្តពង្រឹងការអនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយ និងឲ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ(ពន្ធដារ) និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ។

• បន្តរៀបចំនិងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលក្នុងរយៈពេលមធ្យម ២០១៣-២០១៨។

- ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រតាមប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម ការធ្វើអធិការកិច្ច និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និងឧស្ម័ន ដើម្បីធានាឲ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និងឧស្ម័ន។

- បន្តធ្វើការសិក្សាអំពីវិចារណកម្ម និងលទ្ធភាពវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និងបណ្តាច្បាប់ពាក់ព័ន្ធក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ។

- ពង្រឹងការធ្វើសវនកម្ម ជាពិសេស បន្តពង្រឹងការធ្វើសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ និងការធ្វើសវនកម្មលើសហគ្រាសធំៗសំខាន់ៗឲ្យមានតម្លាភាពក្នុងការប្រកាសបង់ពន្ធឲ្យបានត្រឹមត្រូវ។

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា ព្រមទាំងធនាគារពាណិជ្ជនានា អគ្គិសនីកម្ពុជា កាំកុងត្រូល ដើម្បីប្រមូលព័ត៌មាន និងសហការជាមួយអគ្គស្នងការនគរបាលជាតិ ក្នុងការចាប់បង្ខំឲ្យអ្នកជាប់ពន្ធគោរពប្រតិបត្តិច្បាប់ ព្រមទាំងអនុវត្តវិធានការតឹងទារ ដោយបញ្ឈប់ប្រតិបត្តិការនាំចេញនាំចូល មិនពិនិត្យសំណើសុំនាំចូលតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាត់ទុកប្រាក់ពន្ធនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងការផ្សព្វផ្សាយឈ្មោះក្នុងទំព័រសារព័ត៌មានមុននឹងអនុវត្តវិធានការប្តឹងទៅតុលាការដែលជាជម្រើសចុងក្រោយ។

- ពង្រឹងសេវាអ្នកជាប់ពន្ធ ដោយធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ និងតាមទូរស័ព្ទនូវចម្ងល់ ឬសំណួររបស់អ្នកជាប់ពន្ធ និងបោះពុម្ពជាកូនសៀវភៅ ឬប័ណ្ណពន្យល់ណែនាំដល់អ្នកជាប់ពន្ធ ដើម្បីឲ្យអ្នកជាប់ពន្ធមានការយល់ដឹងពីច្បាប់ស្តីពីសារពើពន្ធ។

- បន្តបណ្តុះបណ្តាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលពន្ធដារឲ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឲ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។

ទី២-ផ្នែកចំណូលពន្ធគយនិងរដ្ឋាករ

- បន្តរៀបចំ និងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលក្នុងរយៈពេលមធ្យម ២០១៣-២០១៨។

- បន្តជំរុញការរៀបចំតាមការចាំបាច់នៃការងារនូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់គយ ពិសេស សម្រាប់បន្តកែលម្អបរិស្ថានធុរកិច្ច និងវិនិយោគ និងសម្រាប់រឹតបន្តឹងវិធានការបំបាត់អំពើរត់ពន្ធគយ។

- បន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ-ចូល ដោយតម្រូវឲ្យមានការរៀបចំជាក្រុមហ៊ុននាំចេញ-ចូល និងក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និងភាពងាយស្រួលក្នុងការត្រួតពិនិត្យ និងក្នុងការយកពន្ធ និងអាករផ្សេងៗ។

- បន្តរៀបចំកែលម្អនិងដាក់ឲ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

- បន្តជំរុញការអនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមានៈ

• បន្តពង្រឹងការអនុវត្តបណ្ដាវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរដែនដី។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឲ្យកាន់តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពថែមទៀតក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសលើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្ដោតលើមុខទំនិញមួយចំនួនដែលមានវេទយិតភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារ អេឡិចត្រូនិច និងការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី។

• បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្ដីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និងកាតព្វកិច្ចពន្ធដារ។

• បន្តរិះរក និងដាក់ឲ្យអនុវត្តនូវវិធានការច្បាស់លាស់ និងទន់ភ្លន់លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយនិងរដ្ឋាករមានជាអាទិ៍ៈ បន្តការបណ្ដុះបណ្ដាល និងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និងសីលធម៌របស់មន្ត្រីគយដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលគយឲ្យបានរឹងមាំ។

- បន្តពង្រឹង និងពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និងយន្តការគ្រប់គ្រងហានិភ័យដើម្បីកែលម្អប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលើកកម្ពស់គុណភាពសេវាកម្មជូនដល់អតិថិជន។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ទី៣-ផ្នែកចំណូលមិនមែនសារពើពន្ធ

- បន្តរៀបចំ និងដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលក្នុងរយៈពេលមធ្យម ២០១៣-២០១៨។

- បន្តពង្រឹង និងជំរុញឲ្យបានជោគជ័យនូវវិធានការកែទម្រង់ការគ្រប់គ្រងកំរៃសេវារដ្ឋបាលរបស់រដ្ឋដែលទើបនឹងត្រូវបានដាក់ចេញក្នុងពេលថ្មីៗកន្លងមក។

- បន្តជំរុញការដាក់ឲ្យអនុវត្តបង្កាន់ដៃជាតិសម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទនៅតាមគ្រប់ក្រសួង ស្ថាប័ន ក្នុងគោលដៅបង្កើនការគ្រប់គ្រង និងការប្រមូលចំណូល។

- បន្តជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ០២ បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

- បន្តជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេស បទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ពិសេស បន្តពង្រឹងការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីធានាឲ្យមានការបង់ចំណូលទាំងនេះចូលថវិកាជាតិឲ្យបានទៀងទាត់ ទាន់ពេលវេលា និងដោយគ្មានការកាត់ទុកសម្រាប់ចំណាយដោយប្រការណាមួយឡើយ។

- បន្តស្រាវជ្រាវ និងកំណត់ឲ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយ បន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះតាមគ្រប់មុខសញ្ញាទាំងអស់។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និងចំណូលពីការជួលរោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូល។

- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើរការផ្តល់ និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទចូលថវិកាជាតិ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឲ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិនៃកម្ពុជា ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលនេះ។

គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

១៩- ពិតណាស់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបាននិងកំពុងធ្វើឲ្យការគ្រប់គ្រងចំណូល និងចំណាយកាន់តែល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែងត្រូវបានឆ្លុះបញ្ចាំងដោយកំណើនឡើងនៃភាពជឿទុកចិត្តលើថវិកា ដែលធ្វើឲ្យរាជរដ្ឋាភិបាលដោះស្រាយបំណុលចាស់បានទាំងស្រុង និងបញ្ឈប់បាននូវប្រពៃណីខ្វះសាច់ប្រាក់ទូទាត់ចំណាយ ហើយថែមទាំងដោះស្រាយបាននូវវិបត្តិសេដ្ឋកិច្ច និងវិបត្តិព្រំដែនក្នុងពេលថ្មីៗកន្លងទៅទៀតផង។ ទន្ទឹមនឹងបញ្ហាប្រឈមចំពោះមុខដែលត្រូវបន្តជំរុញការបង្កើនចំណូលពន្ធដារក្នុងស្រុក ដើម្បីបំពេញនិន្នាការថយចុះនៃចំណូលពន្ធនាំចូល និងហានិភ័យនៃកត្តាខាងក្រៅដែលអាចជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច និងចំណូលជាយថាហេតុ រាជរដ្ឋាភិបាលត្រូវបន្តជំរុញការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធក្នុងការគ្រោងការអនុវត្ត និងការគ្រប់គ្រងចំណូល និងចំណាយ ដើម្បីអាចដោះស្រាយប្រកបដោយប្រសិទ្ធភាពទៅនឹងតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់។ ប្រការនេះ ទាមទារឲ្យរាជរដ្ឋាភិបាល ពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការត្រូវតែបន្តជំរុញបន្ថែមទៀតនូវការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២នេះ ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តលើថវិកាឲ្យកាន់តែរឹងមាំ បន្តបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឲ្យកាន់តែល្អប្រសើរ និងជាបណ្តើរៗបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ តាមរយៈការផ្តោតលើការងារសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

ទី១- *ត្រូវបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឲ្យបានសមស្រប ព្រោះ វាជាមូលដ្ឋានដ៏សំខាន់របស់ក្រសួង ស្ថាប័ន ក្នុងការគូសបញ្ជាក់អំពីគោលបំណងគោលនយោបាយរបស់ខ្លួន ដើម្បីការពារ និងអះអាងលើតម្រូវការចំណាយរបស់ខ្លួន និងដើម្បីជានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។* ត្រូវពង្រឹងការរៀបចំថវិកាឲ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រឹត ដើម្បីកាត់បន្ថយជាអតិបរមានូវចំណាយមិនបានគ្រោងទុក និងសំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និងចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយភាពជឿទុកចិត្តបាន គណនេយ្យភាព និងប្រសិទ្ធភាព។

ទី២- ត្រូវបន្តជំរុញការរៀបចំផែនការលទ្ធកម្ម និងកម្មវិធីចំណូល-ចំណាយឲ្យបានទាន់ពេលវេលា សុក្រឹត និងអនុវត្តឲ្យបានម៉ឺងម៉ាត់ ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ជានាបន្តពង្រឹងភាពជឿទុកចិត្តលើថវិកា បង្កើនគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា។ ទន្ទឹមនឹងនេះ ត្រូវបន្តបង្កើនការគោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងវិន័យថវិកាទាំង១០។

ទី៣- ត្រូវបន្តពង្រឹងការគ្រប់គ្រងបំណុល ពិសេស ការអនុវត្តយុទ្ធសាស្ត្រ និងយន្តការគ្រប់គ្រងបំណុលរបស់រាជរដ្ឋាភិបាល ការកសាងទិន្នន័យ ការរៀបចំកម្មវិធីសងបំណុលឲ្យបានច្បាស់លាស់និងដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងថវិកាប្រចាំឆ្នាំ និងការបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការខ្ចីតែឥណទានសម្បទាន និងដែលបម្រើឲ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

ទី៤- ត្រូវបន្តត្រៀមលក្ខណៈ និងគ្រប់គ្រងឲ្យបានល្អនូវបណ្តាបញ្ហាប្រឈមថ្មី ឬជាយថាហេតុ ដូចជា សម្ពាធអតិផរណា ចំណាយសម្រាប់ដោះស្រាយគ្រោះធម្មជាតិ តម្រូវការចំណាយសម្រាប់ការ ការពារអធិបតេយ្យ និងបូរណភាពទឹកដី ព្រមទាំងកាតព្វកិច្ចអន្តរជាតិ និងកិច្ចប្រជុំផ្សេងៗដែលចេះតែ កើនឡើងជាលំដាប់។

IV- **នីតិវិធី និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០១៤**

ក- ការគ្រោងចំណូលថវិកាឆ្នាំ២០១៤

២០- ការគ្រោងគិតចំណូលចន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផល ទុន ដែលជាប្រភពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង បណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ។
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ។
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ។
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើ អត្រា និងមូលដ្ឋានប្រមូលពន្ធ។
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបានដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និង គោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើ ពន្ធនិងការប្រមូលបំណុលពន្ធដែលត្រូវទារ។
- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឲ្យមានផលទុនដូចជា កិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យ សម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

ខ-ការគ្រោងចំណាយថវិកាឆ្នាំ២០១៤

២១- *ការរៀបចំគម្រោងឥណទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែល បានផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគណនាតម្រូវការថវិកាដោយលម្អិតទៅតាមជំពូក គណនី និងអនុគណនី និងដោយផ្អែកលើតម្រូវការចំណាយជាក់ស្តែង និងដោយផ្ទាល់សម្រាប់អនុវត្តសកម្មភាព ការងារ របស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព ឬផ្នែកនីមួយៗចំណុះឲ្យក្រសួង ស្ថាប័ន និងមន្ទីរ ជំនាញរាជធានី ខេត្ត (តាមគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ) ដើម្បីបម្រើឲ្យកម្មវិធី/យុទ្ធ សាស្ត្រអាទិភាពចាំបាច់ របស់ក្រសួង ស្ថាប័នក្នុងការសម្រេចនូវគោលបំណងគោលនយោបាយរបស់ខ្លួន ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។* រីឯការគណនាឥណទានចំណាយត្រូវផ្អែកទៅ លើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជាតារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតម្លៃសម្ភារៈនៃការ ផ្គត់ផ្គង់ និងត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬសេចក្តីណែនាំ

ដូចជាចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយដំណើរការសាលាសម្រាប់សិស្ស ឬនិស្សិតម្នាក់ ឬត្រូវផ្អែកទៅតាមតួលេខ ស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសម្រាប់ការគ្រប់គ្រងកន្លងមក។ ជាពិសេស តម្រូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និងមានឯកសារគាំទ្រភ្ជាប់មកជាមួយដើម្បីពន្យល់ទៅតាមជំពូក គណនី និងអនុគណនីនីមួយៗ។

គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ២០១៤

២២- រាជរដ្ឋាភិបាលបានធ្វើការកំណត់កញ្ចប់ថវិកា ដោយកំណត់ជាគោលការណ៍ចំណាយទៅតាមប្រភេទ និងជំពូក ដោយផ្អែកលើស្ថានភាព និងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សម្រាប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ធ្វើជាមូលដ្ឋានក្នុងការរៀបចំគម្រោងចំណាយលម្អិតទៅតាមគណនី និងអនុគណនី និងទៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព ឬផ្នែកនីមួយៗចំណុះឲ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក្នុងការអនុវត្តសកម្មភាពការងារជាក់ស្តែង និងចាំបាច់របស់ខ្លួន ដើម្បីបម្រើឲ្យកម្មវិធី/យុទ្ធសាស្ត្រអាទិភាព និងដើម្បីសម្រេចបានតាមគោលដៅនៃគោលបំណងគោលនយោបាយរបស់ខ្លួន ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ***ដូចជាឆ្នាំមុនៗដែរ ការធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវបានអនុញ្ញាតឲ្យធ្វើចាប់ពីត្រីមាសទី៣ គឺបន្ទាប់ពីការអនុវត្តបាន២ត្រីមាស។***

២៣- ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងបណ្តាវិធានការដូចខាងក្រោម៖

ក- **ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤)** ត្រូវគ្រោងទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៣។ រាជរដ្ឋាភិបាលបានគ្រោងកញ្ចប់ថវិការួមមួយសម្រាប់ដំឡើងបៀវត្សឆ្នាំ២០១៤ ប៉ុន្តែដោយសាររាជរដ្ឋាភិបាលកំពុងរៀបចំក្របខ័ណ្ឌ និងយុទ្ធសាស្ត្រសម្រាប់ការដំឡើងបៀវត្សនេះប្រកបដោយសមធម៌ សង្គតិភាព និងប្រសិទ្ធភាព ជាពិសេសដើម្បីធានាឲ្យមានគំលាតសមស្របរវាងអ្នកមានបៀវត្សខ្ពស់ និងទាបព្រមទាំងធានាស្ថិរភាពនិងចីរភាពថវិកា ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈនិងម៉ាក្រូសេដ្ឋកិច្ច គ្រប់ក្រសួង ស្ថាប័ន ត្រូវគ្រោងទៅតាមមូលដ្ឋាននៃក្របខ័ណ្ឌបៀវត្សបច្ចុប្បន្នសិន នៅពេលដែលក្របខ័ណ្ឌនិងយុទ្ធសាស្ត្រនៃការអនុវត្តប្រព័ន្ធបៀវត្សថ្មីត្រូវបានអនុម័ត រាជរដ្ឋាភិបាលនឹងបំពេញបន្ថែមនូវថវិកាសម្រាប់ការអនុវត្តតាមក្របខ័ណ្ឌថ្មីនៃប្រព័ន្ធបៀវត្ស ដល់គ្រប់ក្រសួង ស្ថាប័នជាក្រោយ។ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន និងមិនត្រូវគ្រោងទេ។ ចំពោះការឡើងឋានៈ និងកាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មិនត្រូវគិតអតិផរណានៅក្នុងការគ្រោងចំណាយបៀវត្សនេះទេ។ ចំពោះបុគ្គលិកអណ្តែត និងភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានាចំណាយថវិកាពីក្រសួង

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឲ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ជ្រើសរើស និងប្រើប្រាស់ ។

ខ- ចំណាយសម្រាប់ការទិញ និងសេវា (ជំពូក៦០ ជំពូក៦១ និងជំពូក៦២) ត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃបំផុត ពិសេសលើមុខសញ្ញាទិញឧបករណ៍សម្ភារៈបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណិត ការជួសជុលធំ សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវ និងបេសកកម្មក្រៅប្រទេស ព្រមទាំង សោហ៊ុយចំណាយជាអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី និងទឹកជាដើម។ ការគ្រោងចំណាយឆ្នាំ២០១៤ សម្រាប់ជំពូកការទិញ និងសេវានេះ ត្រូវកំណត់ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ដូច្នេះ មានន័យថាក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវផ្អែកលើកញ្ចប់ឥណទានថវិកាឆ្នាំ២០១៣ នៃជំពូកចំណាយសម្រាប់ការទិញ និងសេវា ហើយកាត់ចេញនូវមុខចំណាយដែលលែងត្រូវការ ឬ/និងមុខចំណាយដែលបម្រើឲ្យសកម្មភាពដែលត្រូវបានបញ្ចប់ រួចធ្វើការរិភាជន៍ឡើងវិញសម្រាប់សកម្មភាពថ្មី ឬ/និងដើម្បីបង្កើនប្រសិទ្ធភាពចំណាយ។

គ- ចំណាយសម្រាប់ការឧបត្ថម្ភធន និងជំនួយសង្គម(ជំពូក៦៥) ត្រូវគ្រោងទៅតាមតម្រូវការចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ចំពោះ ចំណាយដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវអនុវត្តដោយផ្ទាល់ ត្រូវគ្រោងទៅតាមគោលការណ៍ ឬ/និងកិច្ចសន្យា ដែលជាកាតព្វកិច្ចរបស់រដ្ឋ និងនៅជាធរមាន។ ការគ្រោងចំណាយឆ្នាំ២០១៤ សម្រាប់ជំពូកចំណាយឧបត្ថម្ភធន និងជំនួយសង្គមនេះ ត្រូវកំណត់ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ទោះជាក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មានគោលនយោបាយ គោលការណ៍ ឬ/និងកិច្ចសន្យាថ្មីក៏ដោយ។ ដូច្នេះ មានន័យថាក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តត្រូវផ្អែកលើកញ្ចប់ឥណទានថវិកាឆ្នាំ២០១៣ នៃជំពូកចំណាយសម្រាប់ការឧបត្ថម្ភធន និងជំនួយសង្គម ហើយកាត់ចេញនូវមុខចំណាយដែលលែងត្រូវការ ឬ/និងមុខចំណាយដែលបម្រើឲ្យសកម្មភាពដែលត្រូវបានបញ្ចប់ រួចធ្វើការរិភាជន៍ឡើងវិញសម្រាប់សកម្មភាពការងារដែលត្រូវបន្ត និងសម្រាប់គោលនយោបាយ ឬ/និងសកម្មភាពថ្មី ប្រសិនបើមាន ឬ/និងដើម្បីបង្កើនប្រសិទ្ធភាពចំណាយ។ ក្នុងករណីមានគោលនយោបាយ ឬ/និងសកម្មភាពថ្មីដែលការរិភាជន៍ឡើងវិញពីកញ្ចប់ឥណទានថវិកាឆ្នាំ២០១៣ មិនអាចគ្រប់គ្រាន់សម្រាប់បម្រើឲ្យគោលនយោបាយ ឬ/និងសកម្មភាពថ្មីនោះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវលើកគម្រោងចំណាយនោះដោយឡែក ពិសេស សម្រាប់អាជ្ញាធរ គណៈកម្មាធិការ ឧត្តមក្រុមប្រឹក្សា ក្រុមប្រឹក្សា និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងអង្គភាពដែលចំណុះឲ្យក្រសួង ស្ថាប័ន។ ដោយឡែកចំពោះចំណាយដែលត្រូវអនុវត្តដោយអង្គភាពស្វយ័ត ឬអង្គភាពដែលមានថវិកាដោយឡែក ត្រូវគ្រោងដោយផ្អែកលើគោលការណ៍តាមជំពូកដែលបានកំណត់នៅក្នុងចំណុចក និងខ ខាងលើ។ ចំពោះក្រសួង ស្ថាប័ន ដែលត្រូវបន្ត ឬចាប់ផ្តើមអនុវត្តសាកល្បងថវិកាកម្មវិធី ត្រូវរៀបចំគម្រោងចំណាយជាពីរផ្នែក សម្រាប់ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី ទៅតាមគ្រប់ជំពូក គណនី និងអនុគណនី

នីមួយៗ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំងនេះមកការពារគម្រោងថវិកាកម្មវិធីដោយឡែក។

ឃ- ការគណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិកត្រូវផ្អែកលើមូលដ្ឋានពីរគឺៈ ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោង និងប្រសិទ្ធភាពនៃចំណាយ ជាពិសេសដើម្បីមានមូលដ្ឋានច្បាស់លាស់សម្រាប់ធ្វើជាអំណះអំណាងនៃតម្រូវការថវិកា ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវធ្វើការគណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក(ជំពូក៦០ ជំពូក៦១ ជំពូក៦២ និងជំពូក៦៥) ដោយផ្អែកលើមូលដ្ឋានពីរដូចខាងក្រោមៈ

- *កំណត់ចំណាយជាប្រចាំហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះឲ្យបានច្បាស់លាស់*។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយសម្ភារៈផ្គត់ផ្គង់ថែទាំជាប្រចាំ(ដូចជាសម្ភារៈផ្គត់ផ្គង់ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារៈផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជាសម្ភារៈការិយាល័យ ការបោះពុម្ព និងទិញឯកសារ សម្ភារៈបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើ អគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះគួរកំណត់ឲ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឲ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំងវិភាជន៍ទៅតាមនាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។
- *កំណត់ចំណាយមិនជាប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឲ្យបានច្បាស់លាស់*។ ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយបំពាក់ឧបករណ៍សម្ភារៈការិយាល័យ ឧបករណ៍សម្ភារៈដឹកជញ្ជូន សម្ភារៈបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារៈប្រើប្រាស់ផ្សេងៗដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះគួរកំណត់ឲ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ការចំណាយប្រភេទនេះសម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

ង- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គម្រោងចំណូល និងគម្រោងចំណាយថវិកាឆ្នាំ២០១៤ ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាមូលដ្ឋានសម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិកាដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់ការប្រជុំការពារថវិកាទេ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះឲ្យបានទាន់ពេលវេលាដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅ

តែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃថវិកាឆ្នាំ២០១៣ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើសម្រាប់កំណត់គម្រោងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការប្រជុំការពារថវិកា និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ឲ្យបានទាន់ពេលវេលា។

ឃ-ការរៀបចំ និងការវិភាគសំណើនានា

២៤- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ(n-1) ឆ្នាំ២០១៣ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១២ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ២០១៤ ឆ្នាំ(n) ដើម្បីធានាឲ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និងការណែនាំទាំងឡាយខាងលើនេះសម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា៖
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឲ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្តមានការប្រែប្រួល ។
  - ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។
- ផលប៉ះពាល់ដោយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជាអគ្គិសនី ទឹក ប្រេងឥន្ទនៈ សោហ៊ុយដឹកជញ្ជូន និងចំណាយរដ្ឋបាល។ល។

២៥- គម្រោងថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបានលុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ។

២៦- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួល អាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬមានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ។

២៧- បច្ចេកទេសវិភាគដទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និងអត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួនសម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តនីមួយៗ ត្រូវតែបម្រើទៅលើៈ

- ទិសដៅ និងគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

- កម្មវិធី និងយុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសម្រេចបាននូវគោលបំណង និងទិសដៅនៃគោលនយោបាយរបស់ខ្លួន។
- ផែនការសកម្មភាព និងរាល់មធ្យោបាយដំណើរការ ដើម្បីអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព។
- ការគ្រប់គ្រង ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសម្រាប់សម្រេចបានគោលបំណង និងទិសដៅនៃគោលនយោបាយរបស់ខ្លួន។

២៨- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឲ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចាប់ផ្តើមការចរចា និងពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ជាមួយក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឲ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៣ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឲ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៣ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឲ្យបានមុនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣។

V- សេចក្តីសន្និដ្ឋាន

២៩- ខ្លឹមសារនៃសារាចរណែនាំនេះ បានផ្តល់នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងគោលការណ៍ និងនីតិវិធីក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួនឲ្យឆ្លើយតបទៅនឹងកម្មវិធី យុទ្ធសាស្ត្រអាទិភាព ព្រមទាំងទិសដៅ និងគោលបំណងនៃគោលនយោបាយ តាមវិស័យនិងតាមផ្នែករៀងៗខ្លួន សំដៅបម្រើឲ្យបានសម្រេចនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ប្រកបដោយជោគជ័យ គឺការរក្សាកំណើនប្រកបដោយចីរភាពក្នុងរង្វង់ប្រមាណ៧% និងការកាត់បន្ថយភាពក្រីក្រឲ្យបានលើស១% ក្នុងមួយឆ្នាំៗ ព្រមទាំងការបន្តរក្សាឲ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុតក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ភាពសុខដុមរមនាសង្គម និងសុខុមាលភាពរបស់ប្រជាជន។ ដូច្នេះ ដើម្បីឲ្យធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់នោះ ទាមទារឲ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់មានទិសដៅ និងគោលបំណងនៃគោលនយោបាយរបស់ខ្លួន យ៉ាងច្បាស់លាស់ដែលផ្សារភ្ជាប់ទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល មានកម្មវិធី និងយុទ្ធសាស្ត្រអាទិភាពជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវក្នុងការអនុវត្តឆ្ពោះទៅសម្រេចឲ្យបាននូវគោលបំណង និងទិសដៅនៃ

គោលនយោបាយរបស់ខ្លួន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ជាពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៣០- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣ ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាកម្រិតជំនាញ និងបូកសរុបសម្រាប់ការចរចាចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម0,1 លានរៀល។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកា)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត

"ដើម្បីមុខការ "

-ឯកសារ-កាលប្បវត្តិ